# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម


១៣-១០-២០០៥ -ព្រះរាជក្រម នស/រកម/១០០៥/០២២ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីបណ្ណសារ ៦១២៤

១៣-១០-២០០៥ -ព្រះរាជក្រម នស/រកម/១០០៥/០២៣ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្ដីពីការកំណត់សម្គាល់នៃគ្រឿងផ្ទុះប្លាស្ទិកសម្រាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក ៦១៣៥

១៣-១០-២០០៥ -ព្រះរាជក្រម នស/រកម/១០០៥/០២៤ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃពិធីសារស្ដីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃទីតាំងអចិន្ត្រៃយ៍ ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្រ ៦១៦៩

១៣-១០-២០០៥ -ព្រះរាជក្រម នស/រកម/១០០៥/០២៥ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាស្ដីពីការទប់ស្កាត់ និងការដាក់ទោសទៅលើឧក្រិដ្ឋជនទាំងឡាយប្រឆាំងនឹងបុគ្គលដែលត្រូវការការពារជាអន្តរជាតិ រួមទាំងភ្នាក់ងារការទូត ៦១៨៣


### ២. ព្រះរាជក្រឹត្យ


២៣-៧-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៧០៥/៣២៦ ស្ដីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម **ហាវ ប៊ុនសែ** នូវ **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ៦២០២

១៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៣១ ស្ដីពីការតែងតាំងឯកឧត្តម **នូ ទេពីរិទ្ធ** ជាទីប្រឹក្សាសម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកផ្នែកនីតិកម្ម មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ៦២០៣

១៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៣២ ស្ដីពីការតែងតាំងលោកជំទាវ **សំ នារី** ជាជំនួយការសម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ៦២០៤

១៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៣៣ ស្ដីពីការតែងតាំង លោក **ឈន សារ៉ែណ** ជា **ឧកញ៉ា** ៦២០៥

១៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៣៤ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនវរសេនីយ៍ឯក **សំ ប៊ូរ** នាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ៦២០៦

១៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៣៥ ស្តីពីការតែងតាំងឯកឧត្តម **ស៊ាន វិសុទ្ធ** ឧត្តមមន្ត្រីថ្នាក់លេខ ២ជាទីប្រឹក្សារាជរដ្ឋាភិបាលមានឋានៈស្មើ **រដ្ឋលេខាធិការ** ៦២០៧

១៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៣៧ ស្តីពីការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈចំពោះសពឯកឧត្តម **អ៊ឹ គីហ៊ាន** នូវ **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ៦២០៨


## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


១៧-១០-២០០៥ -អនុក្រឹត្យលេខ ១២០ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៦២០៩

២៨-១០-២០០៥ -អនុក្រឹត្យលេខ ១២១ អនក្រ.បក ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៦ ៦២១១

១៧-១០-២០០៥ -អនុក្រឹត្យលេខ ៧៩១ អនក្រ.តត ស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិសំរាប់សភាពាណិជ្ជកម្មរាជធានីភ្នំពេញអាណត្តិទី២ លើកទី ២ ៦២១៣

១៧-១០-២០០៥ -អនុក្រឹត្យលេខ ៧៩២ អនក្រ.តត ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ៦២១៦

១៧-១០-២០០៥ -អនុក្រឹត្យលេខ ៧៩៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦២១៧

២០-១០-២០០៥ -អនុក្រឹត្យលេខ ៧៩៤ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌនាយទាហានពីកងយោធពលខេមរភូមិន្ទ អោយមកបំរើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ៦២១៨

២១-១០-២០០៥ -អនុក្រឹត្យលេខ ៧៩៥ អនក្រ.តត ស្តីពីការតម្លើងថ្នាក់ជូនមន្ត្រីរាជការ ៦២១៩


### ២.សេចក្តីសំរេច


១៨-១០-២០០៥ -សេចក្តីសំរេចលេខ ៤២ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៦២២១


## III.ការងារបណ្តាក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៨-១០-២០០៥ -ប្រកាសលេខ ៧៨១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីសធើន សាន់ ចីប៊ែកខូ បង្កើតរោងចក្រ "ផលិតបារី " ដែលមានឈ្មោះថា "អ៊ីសធើន សាន់ ចីប៊ែកខូ " ៦២២២

១៩-១០-២០០៥ -ប្រកាសលេខ ៧៩៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វេនបូ ស្ព្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី បង្កើតរោងចក្រ "បោះពុម្ពសម្លៀកបំពាក់ " ដែលមាន ឈ្មោះថា "វេនបូ ស្ព្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី " ៦២២៤

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងការពារជាតិ

១៧-១០-២០០៥ -ប្រកាសលេខ០២១/២០០៥ប្រ.កស្តីពីការចេញប័ណ្ណអាវុធខ្លីក្នុងកងយោធពលខេមរភូមិន្ទ ៦២២៦

## ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

១៨-១០-២០០៥ -ប្រកាសលេខ ១៥៣៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ដូនដូង** " ស្ថិតនៅ ក្នុងឃុំ បល្ល័ង្ក ស្រុក បារាយណ៍ ខេត្ត កំពង់ធំ ៦២៣០

១៨-១០-២០០៥ -ប្រកាសលេខ ១៥៣៨ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **អូរត្នោត** " ស្ថិតនៅ ក្នុងឃុំ ងន ស្រុក សណ្តាន់ ខេត្ត កំពង់ធំ ៦២៣១

១៨-១០-២០០៥ -ប្រកាសលេខ ១៥៣៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **រកាជួរ** " ស្ថិតនៅ ក្នុងឃុំ ក្លែង ស្រុក សណ្តាន់ ខេត្ត កំពង់ធំ ៦២៣២

១៨-១០-២០០៥ -ប្រកាសលេខ ១៥៤០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ពោធិ៍មាស** " ស្ថិតនៅ ក្នុងឃុំ អំពិលតាពក ស្រុក អូរាំងឪ ខេត្ត កំពង់ចាម ៦២៣៣

១៨-១០-២០០៥ -ប្រកាសលេខ ១៥៤១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **កំពង់ស្វាយ** " ស្ថិតនៅ ក្នុងឃុំ កំពង់ស្វាយ ស្រុក សេរីសោភ័ណ ខេត្ត បន្ទាយមានជ័យ ៦២៣៤

១៨-១០-២០០៥ -ប្រកាសលេខ ១៥៤២អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " **ប៊ុនរ៉ានី ហ៊ុនសែន ចាន់ថ្លាល** " ទៅជាវិទ្យាល័យ " **ប៊ុនរ៉ានី ហ៊ុនសែន ចាន់ថ្លាល** " ស្ថិតនៅ ក្នុងឃុំ ក្រាំងចេក ស្រុក ឧដុង្គ ខេត្ត កំពង់ស្ពឺ ៦២៣៥

១៨-១០-២០០៥ -ប្រកាសលេខ ១៥៤៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ព្រៃរំដួល** " ស្ថិតនៅ ក្នុងឃុំ ប្រសូតិ ស្រុក ស្វាយទាប ខេត្ត ស្វាយរៀង ៦២៣៦

១៨-១០-២០០៥ -ប្រកាសលេខ ១៥៤៤ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ព្រៃទ័ព** " ស្ថិតនៅ ក្នុងឃុំ ព្រះស្តេច ស្រុក ព្រះស្តេច ខេត្ត ព្រៃវែង ៦២៣៧

## ៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១៨-១០-២០០៥ -ប្រកាសលេខ ២៨៥ ព.ណ ប.អ.ព ប្រ.ក ស្តីពី ការកំណត់កំរៃគ្រប់គ្រងការនាំចេញ ៦២៣៨

២៣-៩-២០០៥ -លិខិតលេខ ២២២១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**រាម វីសេត & ឌីវេឡុបមេន ខូ អិលធីឌី** ៦២៤២

២៧-៩-២០០៥ -លិខិតលេខ ២២២៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អយល៍ ទ័កស៍ (ខេមបូឌា)** ៦២៤៤

២៧-៩-២០០៥ -លិខិតលេខ ២២៣០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប្រាយអរិធី គ្រុប** ៦២៤៦

២៨-៩-២០០៥ -លិខិតលេខ ២២៥៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ្វាញ ស្តារ** ៦២៤៨

២៨-៩-២០០៥ -លិខិតលេខ ២២៥៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខូសមើស៍ (ខេមបូឌា)** ៦២៥០

២៨-៩-២០០៥ -លិខិតលេខ ២២៥៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ព្រោប្រូ ខូ អិលធីឌី** ៦២៥២

២៩-៩-២០០៥ -លិខិតលេខ ២២៥៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អង្គរ ហ្វ៊ូរឈូន អ៊ិនខបតើរេសិន** ៦២៥៤

២៩-៩-២០០៥ -លិខិតលេខ ២២៥៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ផូគីថរ៉ា វីសេត & ស្ប៉ា (ខេមបូឌា)** ៦២៥៦

២៩-៩-២០០៥ -លិខិតលេខ ២២៥៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**លី អ៊ុំអេង** ៦២៥៨

២៩-៩-២០០៥ -លិខិតលេខ ២២៦០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**មេគង្គ ដូម៉ែន** ៦២៦០

២៩-៩-២០០៥ -លិខិតលេខ ២២៦១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឆាយ ហាក់ ហុង គ្រុប អ៊ីមផត អិចផត** ៦២៦២

២៩-៩-២០០៥ -លិខិតលេខ ២២៦៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**៩ ស្ពារ ខូ អិលធីឌី** ៦២៦៤

២៩-៩-២០០៥ -លិខិតលេខ ២២៦៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហ្គោ អ៊ិនធើណេសិនណល អ៊ែរ ត្រេនស្ព័ត (ខេមបូឌា)** ៦២៦៦

២៩-៩-២០០៥ -លិខិតលេខ ២២៦៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ីភូស៊ី** ៦២៦៨

២៩-៩-២០០៥ -លិខិតលេខ ២២៦៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សារ៉ា បូពាំ ខូ អិលធីឌី** ៦២៧០

២៩-៩-២០០៥ -លិខិតលេខ ២២៧០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីនឌី អ៊ីមផត អិចផត** ៦២៧២

២៩-៩-២០០៥ -លិខិតលេខ ២២៧១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេច អាយ ធី (ខេមបូឌា) ឌីវេឡុបមេន** ៦២៧៤

២៩-៩-២០០៥ -លិខិតលេខ ២២៧៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**លីវ៉ាយ ស្ត្រូស (ហុងកុង) លីមីធីត** ៦២៧៦

២៩-៩-២០០៥ -លិខិតលេខ ២២៧៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ីង គីមឆុង ខនស្ត្រាក់សិន** ៦២៧៧

៣០-៩-២០០៥ -លិខិតលេខ ២២៨១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ចាត់ចឺផ្លាយ រៀល អ៊ីស្ទេត ឌីវេឡុបមេន** ៦២៧៩

៣០-៩-២០០៥ -លិខិតលេខ ២២៨២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស្ទីតភូ អិលធីឌី** ៦២៨១

៣០-៩-២០០៥ -លិខិតលេខ ២២៨៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អូស្លូវ អាសូស៊ីអេត** ៦២៨៣

៣០-៩-២០០៥ -លិខិតលេខ ២២៨៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ែតឌីខន ឡូជីស្ទីក (ខេមបូឌា)** ៦២៨៥

# ព្រះរាជក្រម

នស/រកម/១០០៥/០២៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីបណ្ណសារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# បណ្ណសារ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងនិងការថែរក្សាបណ្ណសារដែលជាឯកសារប្រវត្តិសាស្ត្រ និងបញ្ជាក់សិទ្ធិរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិឯកជន សម្រាប់បម្រើការស្រាវជ្រាវសំដៅជំរុញការអភិវឌ្ឍន៍ជាតិ ។

**មាត្រា ២.-**

វាក្យសព្ទដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ :

១-បណ្ណសារ សំដៅឯកសារទាំងឡាយទោះបីស្ថិតក្នុងកាលបរិច្ឆេទក្នុងទម្រង់ ឬ ប្រភេទបែបណាក៏ដោយ ដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិឯកជនបានបង្កើតឡើង ឬ បានទទួលក្នុងការបំពេញសកម្មភាពរបស់ខ្លួន ។

២-បណ្ណសារសាធារណៈ សំដៅបណ្ណសាររដ្ឋបាលដែលក្នុងនោះមានបណ្ណសារចរន្ត អន្តរបណ្ណសារ និងបណ្ណសារស្ថាពរ ។

៣-បណ្ណសារដ្ឋានជាតិនៃកម្ពុជា សំដៅមជ្ឈមណ្ឌលតម្កល់បណ្ណសារដែលស្ថិតនៅក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី ។

៤-បណ្ណសារឯកជន សំដៅឯកសារទាំងឡាយដែលបានបង្កើតឡើង ឬបានទទួលដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិឯកជន ។

៥-ហ្វុង សំដៅបណ្តុំបណ្ណសារដែលក្រសួង ស្ថាប័ន ខេត្ត ក្រុង គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ រូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយបានបង្កើតឡើង ឬ បានទទួល ។

៦-ផែនហ្វុង សំដៅផ្នែកមួយនៃហ្វុង ដែលអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ខេត្ត ក្រុង គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ រូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយបានបង្កើតឡើង ឬ បានទទួល ។

**មាត្រា ៣.-**

បណ្ណសារដែលត្រូវរក្សាទុកជាស្ថាពរនៅបណ្ណសារដ្ឋានជាតិនៃកម្ពុជា ត្រូវបានចាត់ទុកជាបេតិកភណ្ឌជាតិ ។

## ជំពូកទី ២
## លក្ខណៈនៃបណ្ណសារសាធារណៈ

**មាត្រា ៤.-**

បណ្ណសារសាធារណៈមិនត្រូវបានរឹបអូស ផ្ទេរ ឬ ជួញដូរ និងគ្មានអាជ្ញាយុកាល ។

ក្នុងករណីដែលបណ្ណសារសាធារណៈ ស្ថិតក្នុងដៃរូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិឯកជនណាមួយ រដ្ឋអាចទាមទារយកឯកសារទាំងនោះមកវិញបានគ្រប់ពេលវេលា ។

## ជំពូកទី ៣
## ការរៀបចំ និងការថែរក្សាបណ្ណសារសាធារណៈ

**មាត្រា ៥.-**

ការរៀបចំ និងការថែរក្សាបណ្ណសារសាធារណៈស្ថិតក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានបណ្ណសារដ្ឋានជាតិនៃកម្ពុជា ជាអ្នកទទួលបន្ទុក ។

ក្រៅពីតួនាទីប្រមូល ទទួល គ្រប់គ្រង ថែរក្សា សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ បណ្ណសារសាធារណៈ បណ្ណសារដ្ឋានជាតិនៃកម្ពុជាមានភារកិច្ចត្រួតពិនិត្យនិងធ្វើការណែនាំការងារតម្កល់បណ្ណសារសាធារណៈនៅតាមក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ ។

**មាត្រា ៦.-**

ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចប្រមូល រៀបចំ ថែរក្សាបណ្ណសារសាធារណៈរបស់ខ្លួនផ្ទាល់និងបណ្ណសារសាធារណៈនៅតាមបណ្តាអង្គភាពក្រោមឱវាទ ។



5/12

**មាត្រា ៧.-**

ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ត្រូវប្រមូល រៀបចំ ថែរក្សា និង បម្រើឱ្យការស្រាវជ្រាវបណ្ណសារសាធារណៈរបស់ខ្លួន ។

## ជំពូកទី ៤
## ការគ្រប់គ្រងបណ្ណសាររដ្ឋបាល

**មាត្រា ៨.-**

បណ្ណសារចរន្ត ជាឯកសារដែលក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬគ្រឹះស្ថានឯកជន សហគ្រាសឯកជន ដែលទទួលបន្ទុកបម្រើសេវាសាធារណៈបានបង្កើត ឬ បានទទួលនិងដែលកំពុងប្រើប្រាស់ក្នុងសកម្មភាពការងារនៅឡើយ ។

បណ្ណសារចរន្តត្រូវបានគ្រប់គ្រង និងថែរក្សាដោយក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិបុគ្គលនៃនីតិឯកជនដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ៩.-**

អន្តរបណ្ណសារ ជាឯកសារដែលលែងចាត់ទុកថាជាបណ្ណសារចរន្តត្រូវបានគ្រប់គ្រងនិងថែរក្សាដោយបណ្ណសារដ្ឋានរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬគ្រឹះស្ថានឯកជន សហគ្រាសឯកជនដែលទទួលបន្ទុកបម្រើសេវាសាធារណៈ ។

**មាត្រា ១០.-**

បណ្ណសារស្ថាពរ ជាឯកសារដែលបានឆ្លងកាត់ការវាយតម្លៃ និងចាត់ទុកថាជាឯកសារប្រវត្តិសាស្ត្រសម្រាប់បម្រើផលប្រយោជន៍សាធារណៈត្រូវបានថែរក្សាទុកនៅបណ្ណសារដ្ឋានជាតិនៃកម្ពុជា ដោយមិនកំណត់រយៈពេល ។



៤៤

**មាត្រា ១១.-**

ការជ្រើសរើស និងការបំផ្លាញចោលអន្តរបណ្ណសារនៅតាមក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬ គ្រឹះស្ថានឯកជន សហគ្រាសឯកជន ដែលទទួលបន្ទុកបម្រើសេវាសាធារណៈ និងការប្រគល់បណ្ណសារសាធារណៈត្រូវអនុវត្តតាមការណែនាំរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ១២.-**

ការចំណាយក្នុងការរៀបចំ ការគ្រប់គ្រង និងការថែរក្សាបណ្ណសារ ជាបន្ទុកថវិការបស់ក្រសួង ស្ថាប័នជាអាណាព្យាបាល និងជាបន្ទុកថវិការបស់គ្រឹះស្ថានសាធារណៈ ឬសហគ្រាសសាធារណៈ ។

## ជំពូកទី ៥
## ការស្រាវជ្រាវបណ្ណសារសាធារណៈ

**មាត្រា ១៣.-**

បណ្ណសារសាធារណៈ ដែលជាប្រភេទឯកសារផ្សព្វផ្សាយត្រូវបានអនុញ្ញាតឱ្យសាធារណជនស្រាវជ្រាវ និងពិគ្រោះដើម្បីជាព័ត៌មានដោយគ្មានការហាមឃាត់ ។

ចំពោះបណ្ណសារសាធារណៈផ្សេងទៀត ត្រូវបានអនុញ្ញាតឱ្យស្រាវជ្រាវដោយសេរីក្រោយរយៈពេល ២០(ម្ភៃ)ឆ្នាំ គិតចាប់តាំងពីកាលបរិច្ឆេទនៃឯកសារ ឬគិតចាប់ពីថ្ងៃបញ្ចប់សំណុំរឿង ឬក្នុងករណីពិសេស ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

**មាត្រា ១៤.-**

ដើម្បីធានាការការពារអធិបតេយ្យជាតិ ការការពារសន្តិសុខជាតិ និងការការពារសិទ្ធិនៃការរស់នៅរបស់បុគ្គលម្នាក់ៗ បណ្ណសារសាធារណៈត្រូវអនុញ្ញាតឱ្យស្រាវជ្រាវបានក្រោយ

រយៈពេលកំណត់ដូចខាងក្រោម :

-៤០(សែសិប)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃឯកសារ ឬគិតចាប់ពីថ្ងៃបញ្ចប់សំណុំរឿង ចំពោះឯកសារដែលប៉ះពាល់ដល់វិស័យការពារជាតិ សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងសៀវភៅអត្រានុកូលដ្ឋាន លិខិតសារការី និងសំណុំរឿងក្តី ។

ចំពោះឯកសារដែលប៉ះពាល់ដល់វិស័យការពារជាតិ សន្តិសុខជាតិ និង សណ្តាប់ធ្នាប់សាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ ។

-១២០(មួយរយម្ភៃ)ឆ្នាំ គិតចាប់តាំងពីថ្ងៃកំណើត ចំពោះសំណុំឯកសារផ្ទាល់ខ្លួន និងសំណុំឯកសារផ្នែកវេជ្ជសាស្ត្ររបស់បុគ្គលម្នាក់ៗ ។

**មាត្រា ១៥.-**

ដើម្បីបម្រើឱ្យផលប្រយោជន៍សាធារណៈ រាជរដ្ឋាភិបាលអាចសម្រេចកាត់បន្ថយរយៈពេលកំណត់ ដើម្បីអនុញ្ញាតឱ្យធ្វើការស្រាវជ្រាវចំពោះហ្វុង ឬ ផែនហ្វុងនៃហ្វុងណាមួយ ។

ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីសាមី ក្រសួង ស្ថាប័ន ដែលជាអ្នកបង្កើតបណ្ណសារសាធារណៈ បណ្ណសារដ្ឋានជាតិនៃកម្ពុជាអាចអនុញ្ញាតឱ្យស្រាវជ្រាវបណ្ណសារសាធារណៈ មុនរយៈពេលកំណត់ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ។

## ជំពូកទី ៦
## បណ្ណសារឯកជន

**មាត្រា ១៦.-**

បណ្ណសារដ្ឋានជាតិនៃកម្ពុជាអាចទិញ ទទួលជាអំណោយ ឬទទួលជាបញ្ញើនូវបណ្ណសារឯកជនដែលមានតម្លៃជាប្រវត្តិសាស្ត្រ ឬ ជាបេតិកភណ្ឌជាតិ ។

បណ្ណសារដ្ឋានជាតិនៃកម្ពុជាធានាការគ្រប់គ្រង និងការថែរក្សា ព្រមទាំងបម្រើឱ្យការស្រាវជ្រាវបណ្ណសារឯកជននានាបាន ដោយគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។

**មាត្រា ១៧.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលនៃនីតិឯកជនត្រូវផ្តល់ឯកសារ ឬ សំណុំឯកសារមានតម្លៃជាប្រវត្តិសាស្ត្រ ឬ ជាបេតិកភណ្ឌជាតិចំនួនមួយច្បាប់ ដល់បណ្ណសារដ្ឋានជាតិនៃកម្ពុជាក្នុងពេលអនុវត្តសកម្មភាពរបស់ខ្លួននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

ឯកសារ ឬ សំណុំឯកសារដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៧
## ក្រុមប្រឹក្សាបណ្ណសារ

**មាត្រា ១៨.-**

ត្រូវបង្កើតឡើងនូវក្រុមប្រឹក្សាបណ្ណសារដែលមានភារកិច្ច :

-ធ្វើសំណើអំពីគោលនយោបាយក្នុងការគ្រប់គ្រងបណ្ណសារ

-កំណត់គោលការណ៍ និងនីតិវិធីក្នុងការជ្រើសរើស ការវាយតម្លៃ ការបំផ្លាញចោលអន្តរបណ្ណសារ ការរក្សាទុកបណ្ណសារស្ថាពរ និងអំពីរយៈពេលកំណត់ ក្នុងការប្រគល់នូវបណ្ណសារសាធារណៈ

-ផ្តល់យោបល់ទាក់ទងនឹងបណ្ណសារឯកជនដែលមានតម្លៃជាប្រវត្តិសាស្ត្រ ឬ ជាបេតិកភណ្ឌជាតិ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ១៩.-**

មន្ត្រី ឬ បុគ្គលិករដ្ឋបាលទទួលបន្ទុកថែរក្សាបណ្ណសារសាធារណៈ ដែលបានផ្តល់ព័ត៌មានរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់

ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ៤.០០០.០០០(បួនលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ទៅ ១(មួយ)ឆ្នាំ ពីបទរំលោភលើការសម្ងាត់វិជ្ជាជីវៈ ។

មន្ត្រី ឬបុគ្គលិករដ្ឋបាលទទួលបន្ទុកថែរក្សាបណ្ណសារសាធារណៈ ដែលបានផ្តល់ព័ត៌មានរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ លើកលែងតែបណ្ណសារសាធារណៈដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន)រៀល ទៅ ៨.០០០.០០០ (ប្រាំបីលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ ពីបទរំលោភលើការសម្ងាត់វិជ្ជាជីវៈ ។

ក្នុងករណីបទល្មើសខាងលើដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ៧(ប្រាំពីរ)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ ។

ការសមគំនិត ឬ ការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តន្ទាទោសដូចគ្នា ។

**មាត្រា ២០.-**

មន្ត្រី ឬ បុគ្គលិករដ្ឋបាលដែលបានធ្វើឱ្យខូចគុណភាព តែបំបាត់ ជួញដូរ ឬ នាំចេញទៅបរទេសនូវបណ្ណសារសាធារណៈ ដោយរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី) ឆ្នាំ ។

មន្ត្រី ឬ បុគ្គលិករដ្ឋបាលដែលបានធ្វើឱ្យខូចគុណភាព តែបំបាត់ ជួញដូរ ឬនាំចេញទៅបរទេសនូវបណ្ណសារសាធារណៈ ដោយរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ លើកលែងតែបណ្ណសារសាធារណៈដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ ឬ សណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀលនិងផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំទៅ ៥(ប្រាំ)ឆ្នាំ ។

ក្នុងករណីបទល្មើសខាងលើ ដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ



10/12

ឬសណ្តាប់ធ្នាប់សាធារណៈត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០.០០០.០០០(ដប់លាន)រៀល ទៅ ៥០.០០០.០០០(ហាសិបលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ)ឆ្នាំ ទៅ ៣០(សាមសិប)ឆ្នាំ ។

ការសមគំនិត ឬ ការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តន្ទាទោសដូចគ្នា ។

**មាត្រា ២១.-**

ជនណាដែលបានធ្វើឱ្យខូចគុណភាព បំផ្លាញ តែបំបាត់ ជួញដូរ ឬ នាំចេញទៅបរទេស នូវបណ្ណសារសាធារណៈ ដែលរក្សាទុកនៅក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បណ្ណសារដ្ឋានជាតិនៃកម្ពុជា គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ឬ គ្រឹះស្ថានឯកជន សហគ្រាសឯកជនដែលទទួលបន្ទុកបម្រើសេវាសាធារណៈ ដោយរំលោភលើបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ ។

ជនណាដែលបានធ្វើឱ្យខូចគុណភាព បំផ្លាញ តែបំបាត់ ជួញដូរ ឬ នាំចេញទៅបរទេស នូវបណ្ណសារសាធារណៈ ដោយរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ លើកលែងតែបណ្ណសារសាធារណៈ ដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ ឬ សណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ ។

ក្នុងករណីបទល្មើសខាងលើ ដែលទាក់ទងនឹងវិស័យការពារជាតិ សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០(ហាសិបលាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

ការសមគំនិត ឬ ការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តន្ទាទោសដូចគ្នា ។

**មាត្រា ២២.-**

មន្ត្រី បុគ្គលិករដ្ឋបាល ឬ ជនណាដែលបានធ្វើឱ្យខូចគុណភាព បំផ្លាញ តែបំបាត់ ផ្ទេរ ឬ នាំចេញទៅបរទេសនូវបណ្ណសារឯកជនដែលគ្រប់គ្រងដោយបណ្ណសារដ្ឋានជាតិនៃកម្ពុជា ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៨ (ប្រាំបី)ឆ្នាំ ។

ការសមគំនិត ឬ ការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តន្ទាទោសដូចគ្នា ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រ.ល.០៥១០.៤៥២ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខ: ៧០៤៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ១០ ឆ្នាំ ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាង តាន់**

# ព្រះរាជក្រម

នស/រកម/១០០៥/០២៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាស្តីពីការកំណត់សម្គាល់នៃគ្រឿងផ្ទុះប្លាស្ទិកសម្រាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាស្តីពីការកំណត់សម្គាល់នៃគ្រឿងផ្ទុះប្លាស្ទិក សម្រាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីការកំណត់សម្គាល់នៃគ្រឿងផ្ទុះប្លាស្ទិកសម្រាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក ដែលធ្វើនៅទីក្រុងម៉ុងរ៉េអាល់ នាថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

**មាត្រា ៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥

នស/រកម.១០០៥.០២៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងការពារជាតិ**

ហត្ថលេខា

ទៀ បាញ់ ញឹក ប៊ុនឆៃ

លេខ : ៣៧១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ចិន្តាស៊ីណា តាន់

# ឧបសម្ព័ន្ធ I
# អនុសញ្ញាស្តីពី ការកំណត់សំគាល់
# នៃគ្រឿងផ្ទុះប្លាស្ទិកសំរាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក

**រដ្ឋភាគីនៅនឹងអនុសញ្ញា :**

-ដោយដឹងថាមានការជាប់ទាក់ទងអំពើភេរវកម្មចំពោះសន្តិសុខអន្តរជាតិ

-ដោយមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអំពើភេរវកម្ម បានប៉ុនប៉ងបំផ្លិចបំផ្លាញយន្តហោះ មធ្យោបាយដឹកជញ្ជូននានា និងគោលដៅផ្សេងៗទៀត

-ដោយព្រួយបារម្ភថាគ្រឿងផ្ទុះប្លាស្ទិកត្រូវបានប្រើប្រាស់សំរាប់ភេរវកម្ម

-ដោយពិចារណាឃើញថា ការកំណត់សំគាល់គ្រឿងផ្ទុះប្រភេទប្លាស្ទិកជាកម្មវត្ថុនៃការស្រាវជ្រាវរក អាចជាជំនួយយ៉ាងសំខាន់ដើម្បីទប់ស្កាត់អំពើខុសច្បាប់

-ដោយទទួលស្គាល់ថា វត្ថុបំណងដើម្បីរាំងអំពើខុសច្បាប់បែបនេះ ជាតម្រូវការចាំបាច់ជាបន្ទាន់សំរាប់បណ្តារដ្ឋ ដែលគោរពតាមលិខិតុបករណ៍អន្តរជាតិដើម្បីអនុម័តវិធានការសមស្របសំដៅធានាថា គ្រឿងផ្ទុះប្លាស្ទិកត្រូវបានកំណត់សំគាល់ដ៏ត្រឹមត្រូវ

-ដោយពិចារណាឃើញថា សេចក្តីសំរេចនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ៦៣៥ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ១៩៨៩ និងសេចក្តីសំរេចនៃមហាសន្និបាតអង្គការសហប្រជាជាតិលេខ ៤៤-២៩ ចុះថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ១៩៨៩ ដែលជំរុញអោយអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដើម្បីតែបន្ថែមកិច្ចការរបស់ខ្លួនក្នុងការបង្កើត ប្រព័ន្ធអន្តរជាតិសំរាប់ការកត់សំគាល់គ្រឿងផ្ទុះប្លាស្ទិក ឬបន្ទុះគ្រឿងផ្ទុះដែលជាកម្មវត្ថុនៃការស្រាវជ្រាវរក

-ដោយបានគិតគូរយកចិត្តទុកដាក់ទៅនឹងសេចក្តីសំរេច A ២៧-៨ ដែលបានអនុម័តជាឯកច្ឆ័ន្ទនាសម័យប្រជុំលើកទី ២៧ នៃសន្និបាតអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដែលបានយល់ព្រមប្រកបដោយអទិភាពខ្ពស់ និងលើសលប់ទៅនឹងការរៀបចំលិខិតុបករណ៍អន្តរជាតិថ្មីមួយសំរាប់កំណត់សំគាល់គ្រឿងផ្ទុះប្លាស្ទិក ឬបន្ទុះគ្រឿងផ្ទុះ ដែលត្រូវស្រាវជ្រាវរក

-ដោយមានការកត់សំគាល់ដោយក្តីសោមនស្ស ដល់តួនាទីរបស់ក្រុមប្រឹក្សាអាកាសចរណ៍ស៊ីវិលអន្តរជាតិ ក្នុងការរៀបចំអនុសញ្ញានេះ ក៏ដូចជាឆន្ទៈរបស់ក្រុមប្រឹក្សាអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដើម្បីទទួលភារកិច្ចមុខងារ ដែលជាប់ពាក់ព័ន្ធនឹងការអនុវត្តន៍របស់ខ្លួន

**បានព្រមព្រៀងដូចខាងក្រោម :**

## មាត្រា ១
## គោលបំណងនៃអនុសញ្ញានេះ

១-"គ្រឿងផ្ទុះ" មានន័យថា ផលិតផលជាតិផ្ទុះដែលទូទៅគេស្គាល់ថាជា "គ្រឿងផ្ទុះប្លាស្ទិក" រួមមានប្រភេទគ្រឿងផ្ទុះទាំងឡាយដែលមានទ្រង់ទ្រាយជាបន្ទះយឺត ឬបត់បែនបានដូចមានចែងនៅក្នុងឧបសម្ព័ន្ធបច្ចេកទេស នៃអនុសញ្ញានេះ ។

២-"សារធាតុភ្នាក់ងាររុករក" មានន័យថាសារធាតុមួយដូចមាន ចែងក្នុងឧបសម្ព័ន្ធបច្ចេកទេសនៃអនុសញ្ញា នេះ ដែលត្រូវបាន ដាក់បញ្ចូលទៅក្នុងគ្រឿងផ្ទុះដើម្បីធ្វើអោយសារធាតុមួយនេះអាចស្រូបបាន ។

៣-"ការដាក់សំគាល់" មានន័យថា ការដាក់បញ្ចូលទៅក្នុងគ្រឿងផ្ទុះនូវ សារធាតុភ្នាក់ងាររុករកដោយអនុលោមតាមឧបសម្ព័ន្ធបច្ចេកទេស នៃអនុសញ្ញានេះ ។

៤-"ការផលិត" មានន័យថាជាដំណើរការផលិត ដោយរាប់ទាំងដំណើរការផលិតជាថ្មីនៃការផលិត គ្រឿងផ្ទុះ ។

៥-"ឧបករណ៍ស្របច្បាប់" ត្រូវមាន ប៉ុន្តែមិនកំរិតចំពោះ គ្រាប់កាំភ្លើងធំ គ្រាប់បែកធំៗ គ្រាប់បាញ់រយៈចំងាយឆ្ងាយ គ្រាប់មីន គ្រាប់មីស៊ីល គ្រាប់រ៉ុកកែត វិសេវផ្ទុះ គ្រាប់បែកដៃ ហើយនិងគ្រឿង ទំលុះដែលផលិតឡើងយ៉ាងពិសេសសំរាប់គោលបំណងយោធា និងប៉ូលីសស្របតាមច្បាប់ និងបទបញ្ជារបស់ រដ្ឋភាគីដែលជាប់ពាក់ព័ន្ធ ។

៦-"រដ្ឋផលិត" មានន័យថា រដ្ឋដែលនៅក្នុងទឹកដីរបស់ខ្លួនមានគ្រឿងផ្ទុះត្រូវបានផលិត ។

## មាត្រា ២

រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់ និងមានប្រសិទ្ធិភាពដើម្បីហាមឃាត់ និងទប់ស្កាត់ការផលិតនៅក្នុងទឹកដីរបស់ខ្លួននូវគ្រឿងផ្ទុះមិនសំគាល់បាន ។

## មាត្រា ៣

១-រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់នានា និងមានប្រសិទ្ធិភាពដើម្បីហាមឃាត់ និងទប់ស្កាត់ការចល័តទាំងនៅខាងក្នុង ឬនៅខាងក្រៅនៃទឹកដីរបស់ខ្លួននូវគ្រឿងផ្ទុះទាំងឡាយមិនសំគាល់បាន ។

២-ចំពោះវាក្យខ័ណ្ឌខាងលើនឹងមិនយកមកអនុវត្ត ចំពោះការចល័តក្នុងបំណងមិនស្របទៅនឹងគោលបំណង នៃអនុសញ្ញាដោយអាជ្ញាធរនៃរដ្ឋភាគី ចំពោះមុខងារជាយោធា ឬប៉ូលីសនូវគ្រឿងផ្ទុះទាំងឡាយ ដែលមិនសំគាល់បាន ហើយស្ថិតនៅក្រោមការត្រួតពិនិត្យនៃរដ្ឋជាភាគីនោះ ដូចមានចែងក្នុងវាក្យខ័ណ្ឌ១ នៃមាត្រា៤ ។

## មាត្រា ៤

១-រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់នានា ដើម្បីអនុវត្តម៉ឺងម៉ាត់ និងត្រួតពិនិត្យដ៏មានប្រសិទ្ធភាព ទៅលើកម្មសិទ្ធិ និងការផ្ទេរកម្មសិទ្ធិនៃគ្រឿងផ្ទុះមិនសំគាល់បាននេះ ដែលត្រូវបានផលិតនៅក្នុង ឬនាំចូលមកក្នុងទឹកដីរបស់ខ្លួន មុនពេលអនុសញ្ញានេះ ចូលជាធរមានចំពោះរដ្ឋនោះ ដើម្បីទប់ស្កាត់ការប្រើប្រាស់ខុសទិសដៅ ឬមិនស្របតាមគោលបំណងនៃអនុសញ្ញានេះ ។

២_រដ្ឋភាគីនិមួយៗត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាថា រាល់ការស្តុកនៃគ្រឿងផ្ទុះទាំងឡាយមិនសំគាល់បានដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ហើយដែលមិនកាន់កាប់ដោយអាជ្ញាធររបស់ខ្លួន ដែលមានមុខងារជាយោធា ឬប៉ូលីស នោះត្រូវកំទេចចោល ឬដុតបំផ្លាញចោល ប្រសិនបើការប្រើប្រាស់នោះមិនស្របទៅនឹងគោលបំណង នៃអនុសញ្ញានេះ ដោយបញ្ជាក់ច្បាស់ ឬបានធ្វើអោយអស់ប្រសិទ្ធិភាពជាអចិន្ត្រៃយ៍ក្នុងរយៈពេល ៣ ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋនោះ ។

៣_ រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់នានាដើម្បីធានាថា ការស្តុកទាំងអស់នៃគ្រឿងផ្ទុះទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១នៃមាត្រានេះ ហើយដែលកាន់កាប់ដោយអាជ្ញាធររបស់ខ្លួន ដែលមានមុខងារជាយោធា ឬប៉ូលីស ហើយដែលមិនបានបញ្ចូលជាផ្នែកតែមួយ នៃយុទ្ធោបករណ៍ស្របច្បាប់ គឺត្រូវកំទេចចោល ឬធ្វើអោយអស់ប្រសិទ្ធិភាព ប្រសិនបើការប្រើប្រាស់នោះមិនស្របទៅនឹងគោលបំណងនៃអនុសញ្ញានេះដោយបង្ហាញ ឬបញ្ជាក់ថាបានធ្វើអោយអស់ប្រសិទ្ធភាពជាអចិន្ត្រៃយ៍ក្នុងរយៈពេល ១៥ ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋនោះ ។

៤_រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាដល់ការបំផ្លាញអោយបានឆាប់រហ័សបំផុត តាមដែលអាចធ្វើទៅបានក្នុងទឹកដីរបស់ខ្លួន នូវគ្រឿងផ្ទុះទាំងឡាយដែលមិនសំគាល់បាន ហើយដែលអាចត្រូវបានរកឃើញនៅនឹងកន្លែង ហើយដែលមិនមានចែងនៅក្នុងកថាខ័ណ្ឌខាងដើមនៃមាត្រានេះ ក្រៅអំពីស្តុកនៃគ្រឿងផ្ទុះទាំងឡាយមិនសំគាល់បាន ហើយដែលកាន់កាប់ដោយអាជ្ញាធររបស់ខ្លួន ដែលមានមុខងារជាយោធា ឬប៉ូលីស និងមិនបានបញ្ចូលជាផ្នែកតែមួយនៃយុទ្ធោបករណ៍ស្របច្បាប់នៅថ្ងៃ ដែលអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋនោះ ។

៥_រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់នានាដើម្បីអនុវត្តម៉ឺងម៉ាត់ និងមានប្រសិទ្ធិភាពក្នុងការត្រួតពិនិត្យទៅលើកម្មសិទ្ធិ និងការផ្ទេរកម្មសិទ្ធិនៃគ្រឿងផ្ទុះទាំងឡាយដូចមានចែងនៅក្នុងកថាខ័ណ្ឌ ២ នៃភាគ ១ នៃឧបសម្ព័ន្ធបច្ចេកទេសនៃអនុសញ្ញានេះ ដើម្បីទប់ស្កាត់ការប្រើប្រាស់ខុសទិសដៅ ឬការប្រើប្រាស់មិនសមស្របទៅនឹងវត្ថុបំណងនៃអនុសញ្ញានេះ ។

៦_រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាដល់ការបំផ្លាញអោយបានឆាប់រហ័សបំផុត តាមការដែលអាចធ្វើទៅបាន នៅក្នុងទឹកដីរបស់ខ្លួននូវគ្រឿងផ្ទុះទាំងឡាយមិនអាចសំគាល់បាន ដែលបានផលិតចាប់តាំងពីអនុសញ្ញានេះបានចូលជាធរមានចំពោះរដ្ឋនោះ ហើយដែលមិនមានចែងជាក់លាក់នៅក្នុងវាក្យខ័ណ្ឌ ២ d នៃភាគ ១ នៃឧបសម្ព័ន្ធបច្ចេកទេសនៃអនុសញ្ញានេះហើយនិងគ្រឿងផ្ទុះទាំងឡាយមិនសំគាល់បានជាច្រើនទៀត ដែលមិនមានចែងនៅក្នុងវាក្យខ័ណ្ឌផ្សេងៗនៃកថាខ័ណ្ឌ II នៃឧបសម្ព័ន្ធបច្ចេកទេស ។

## មាត្រា ៥

១_មានការបង្កើតឡើងដោយអនុសញ្ញានេះ នូវគណៈកម្មការបច្ចេកទេសគ្រឿងផ្ទុះអន្តរជាតិមួយ (ក្រោយមកហៅថា គណៈកម្មការ ) ដែលមានសមាជិកមិនតិចជាង ១៥ នាក់ ហើយក៏មិនលើសពី ១៩ នាក់ ហើយដែលត្រូវបានតែង

តាំងឡើងដោយក្រុមប្រឹក្សានៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ក្រោយមកហៅថា ក្រុមប្រឹក្សា) ដែលសមាជិកទាំងនោះត្រូវបានតែងតាំងពីក្នុងចំណោមបណ្តារដ្ឋភាគីនៃអនុសញ្ញានេះ ។

២_សមាជិកនៃគណៈកម្មការនេះត្រូវតែជាអ្នកឯកទេស ដែលមានបទពិសោធន៍ច្រើន និងដោយផ្ទាល់ក្នុងរាល់កិច្ចការដែលជាប់ទាក់ទងទៅនឹងការផលិត ការសិក្សាស្វែងយល់ និងការស្រាវជ្រាវអំពីគ្រឿងផ្ទុះ ។

៣_សមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវបំរើការងាររយៈពេល ៣ ឆ្នាំ ហើយអាចនឹងត្រូវបានជ្រើសតាំងជាថ្មីបន្តទៀត ។

៤_សម័យប្រជុំនៃគណៈកម្មការនេះត្រូវកោះប្រជុំយ៉ាងតិច ១ ដងក្នុងមួយឆ្នាំ នៅទីស្នាក់ការនៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ឬនៅកន្លែងនិងពេលវេលា ដែលកំណត់ ឬសំរេចដោយក្រុមប្រឹក្សា ។

៥_ គណៈកម្មការនេះត្រូវអនុម័តនូវច្បាប់នៃនីតិវិធីរបស់ខ្លួន ដោយមានការយល់ព្រមពីក្រុមប្រឹក្សា ។

## មាត្រា ៦

១_ គណៈកម្មការត្រូវវាយតំលៃ ការអភិវឌ្ឍន៍ផ្នែកបច្ចេកទេសដែលទាក់ទងទៅនឹងការផលិត ការកំណត់សំគាល់ និងការស្រាវជ្រាវរកគ្រឿងផ្ទុះ ។

២_តាមរយៈក្រុមប្រឹក្សាគណៈកម្មការនេះត្រូវរាយការណ៍ ការរកឃើញរបស់ខ្លួនទៅរដ្ឋភាគី និងអង្គការអន្តរជាតិដែលពាក់ព័ន្ធ ។

៣_គ្រប់ពេលដែលចាំបាច់គណៈកម្មការ ត្រូវធ្វើអនុសាសន៍ផ្ញើជូនទៅក្រុមប្រឹក្សា ដើម្បីធ្វើវិសោធនកម្មលើឧបសម្ព័ន្ធបច្ចេទេស នៃអនុសញ្ញានេះ ។ គណៈកម្មការត្រូវខិតខំប្រឹងប្រែងដើម្បីធ្វើសេចក្តីសំរេចចិត្តរបស់ខ្លួន លើអនុសាសន៍ដោយសំឡេងកុងសង់ស៊ីស ។ ក្នុងករណីដែលមិនមានកុងសង់ស៊ីស គណៈកម្មការត្រូវធ្វើសេចក្តីសំរេចដោយការបោះឆ្នោតយកសម្លេងភាគច្រើន ២/៣ នៃសមាជិកទាំងមូល ។

៤_យោងតាមអនុសាសន៍របស់គណៈកម្មការក្រុមប្រឹក្សា អាចដាក់ស្នើទៅរដ្ឋភាគីដើម្បីធ្វើវិសោធនកម្មលើឧបសម្ព័ន្ធបច្ចេកទេស នៃអនុសញ្ញានេះបាន ។

## មាត្រា ៧

១_រដ្ឋភាគីនីមួយៗអាចបញ្ជូនសេចក្តីពន្យល់របស់ខ្លួនទៅក្រុមប្រឹក្សា បានក្នុងរយៈពេល ៩០ថ្ងៃ ចាប់ពីថ្ងៃ ដែលបានប្រកាសជូនដំណឹងអំពីសំណើវិសោធនកម្ម ទៅលើឧបសម្ព័ន្ធបច្ចេកទេស នៃអនុសញ្ញានេះ ។ ក្រុមប្រឹក្សាត្រូវបញ្ជូនសេចក្តីពន្យល់នេះទៅគណៈកម្មការ អោយបានឆាប់រហ័សតាមការដែលអាចធ្វើទៅបាន ដើម្បីគណៈកម្មការធ្វើការពិចារណា។ ក្រុមប្រឹក្សាត្រូវអញ្ជើញរដ្ឋភាគី ដែលបានផ្តល់សេចក្តីពន្យល់ ឬការជំទាស់របស់ខ្លួន លើសំណើវិសោធនកម្ម ដែលបានស្នើឡើងនេះ ដើម្បីពិគ្រោះជាមួយគណៈកម្មការ ។

២-គណៈកម្មការត្រូវពិចារណាយោបល់ របស់រដ្ឋភាគីទាំងឡាយដែលបានស្នើឡើង ដោយអនុលោមតាមកថា-ខ័ណ្ឌខាងលើ ហើយត្រូវរាយការណ៍ជូនមក ក្រុមប្រឹក្សា ។ ក្រុមប្រឹក្សា បន្ទាប់ពីធ្វើការពិចារណាលើរបាយការណ៍ របស់គណៈកម្មការ និងធ្វើការវិភាគទៅលើខ្លឹមសារនៃវិសោធនកម្ម និងសេចក្តីពន្យល់របស់រដ្ឋភាគីទាំងអស់គិតទាំងរដ្ឋដែលជាអ្នកស្នើផង មុននឹងដាក់សំណើវិសោធនកម្មជូនរដ្ឋភាគីទាំងអស់ដើម្បីធ្វើការអនុម័ត ។

៣-ប្រសិនបើសំណើវិសោធនកម្ម ដែលដាក់ស្នើនេះមិនមានការជំទាស់ពីរដ្ឋភាគីចំនួនប្រាំ ឬលើសពីនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមក ក្រុមប្រឹក្សា ក្នុងរយៈពេល៩០ថ្ងៃ ចាប់ពីថ្ងៃដែលបានប្រកាសជូនដំណឹងអំពីសំណើវិសោធ-នកម្មដោយ ក្រុមប្រឹក្សា នោះចាត់ទុកថាសំណើវិសោធនកម្មត្រូវបានទទួលការអនុម័ត ហើយនឹងចូលជាធរមាន ក្រោយពីរយៈពេលមួយរយប៉ែតសិបថ្ងៃ ឬក្រោយពីថ្ងៃបរិច្ឆេទដូចមានចែងនៅក្នុងសំណើវិសោធនកម្ម ដែលបានស្នើចំពោះរដ្ឋភាគីទាំងនោះដែលមិនបានសំដែងការជំទាស់ ។

៤-រដ្ឋភាគីដែលបានសំដែងការជំទាស់ ទៅនឹងសំណើវិសោធនកម្មអាចទទួលយកជាការវិញ ដោយប្រើមធ្យោបាយជាលិខិតុបករណ៍បញ្ជាក់ពីការព្រមទទួលយក ឬការយល់ព្រមរបស់ខ្លួន នូវ ខ ទាំងឡាយនៃវិសោធនកម្ម ។

៥-ប្រសិនបើរដ្ឋភាគីចំនួន៥ ឬលើសពីនេះបានជំទាស់ទៅនឹងសំណើវិសោធនកម្ម ក្រុមប្រឹក្សា ត្រូវបញ្ជូនសំណើវិសោធនកម្មនេះជូនទៅ គណៈកម្មការ ដើម្បីធ្វើការពិចារណាថែមទៀត ។

៦-ប្រសិនបើសំណើវិសោធនកម្មនេះ មិនត្រូវបានទទួលការអនុម័តយោងតាមកថាខ័ណ្ឌ ៣ នៃមាត្រានេះ ក្រុមប្រឹក្សា អាចកោះប្រជុំជាសន្និសីទនៃបណ្តារដ្ឋភាគីទាំងអស់ ។

## មាត្រា ៨

១-ប្រសិនបើអាច រដ្ឋភាគីត្រូវផ្តល់ទៅក្រុមប្រឹក្សានូវពត៌មានដែលអាចជួយដល់ គណៈកម្មការ ក្នុងការខកខានមិនបានបំពេញមុខងាររបស់ខ្លួន ស្របតាមកថាខ័ណ្ឌ ១ នៃមាត្រា ៦ ។

២-រដ្ឋភាគីត្រូវរក្សាការផ្តល់ដំណឹងដល់ ក្រុមប្រឹក្សា រាល់វិធានការនានាដែល គណកម្មការ បានយកមកអនុវត្តនូវ ខ ទាំងឡាយនៃអនុសញ្ញានេះ ។ ក្រុមប្រឹក្សា ត្រូវប្រាប់ដំណឹងនេះទៅរដ្ឋភាគីទាំងអស់ និងអង្គការអន្តរជាតិនានា ដែលជាប់ពាក់ព័ន្ធ ។

## មាត្រា ៩

ក្រុមប្រឹក្សា ដោយមានកិច្ចសហប្រតិបត្តិការពីរដ្ឋភាគីទាំងអស់ និងអង្គការអន្តរជាតិនានា ដែលជាប់ពាក់ព័ន្ធត្រូវចាត់វិធានការទាំងឡាយសមស្រប ដើម្បីជួយសំរួលដល់ការអនុវត្តន៍នៃអនុសញ្ញានេះ ព្រមទាំង ខ ទាំងឡាយ ស្តីពីជំនួយបច្ចេកទេស និងវិធានផ្សេងៗទៀត សំរាប់ជាការផ្លាស់ប្តូរពត៌មានទៅវិញទៅមកដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍បច្ចេកទេសក្នុងការដាក់សំគាល់ និងការស្រាវជ្រាវគ្រឿងផ្ទុះ ។

## មាត្រា ១០

ឧបសម្ព័ន្ធបច្ចេកទេសភ្ជាប់ទៅនឹងអនុសញ្ញានេះ បង្កើតជាផ្នែកមួយបន្ថែមទៀតនៃអនុសញ្ញានេះ ។

## មាត្រា ១១

១~ ជម្លោះរវាងរដ្ឋភាគី ពីរ ឬច្រើនទៅនឹងការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះដែលមិនអាចដោះស្រាយបានតាមការចរចា អាចធ្វើសំណើដោយរដ្ឋភាគីមួយក្នុងចំណោមរដ្ឋភាគីទាំងអស់ទៅគណៈវិនិច្ឆ័យ ។ ប្រសិនបើក្នុងរយៈពេលប្រាំមួយខែគិតចាប់ពីថ្ងៃស្នើសុំធ្វើការវិនិច្ឆ័យ ហើយរដ្ឋភាគីមិនអាចយល់ព្រមលើការរៀបចំរបស់គណៈវិនិច្ឆ័យនេះទេ រដ្ឋភាគីមួយនៃរដ្ឋភាគីទាំងនោះអាចបញ្ជូនជម្លោះឡើងតុលាការយុត្តិធម៌អន្តរជាតិ ដោយធ្វើសំណើអនុលោមតាមលក្ខន្តិកៈរបស់តុលាការ ។

២~ នៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ផ្តល់ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិកនៃអនុសញ្ញានេះ រដ្ឋភាគីអាចប្រកាសថាខ្លួនមិនបានចាត់ទុកថាត្រូវបានចងភ្ជាប់ដោយកថាខ័ណ្ឌខាងលើទេ ។ រដ្ឋភាគីផ្សេងទៀតនឹងមិនត្រូវបានចងភ្ជាប់ដោយកថាខ័ណ្ឌខាងលើ ចំពោះរដ្ឋភាគីណាមួយដែលបានដាក់លក្ខខ័ណ្ឌបែបនេះដែរ ។

៣~រដ្ឋភាគីណាមួយដែលបានបង្កើតល័ក្ខខ័ណ្ឌ ដោយយោងតាមវាក្យខ័ណ្ឌខាងលើ អាចដកល័ក្ខខ័ណ្ឌនេះវិញបានដោយជូនដំណឹងទៅគណៈកម្មការទទួលបន្ទុក ។

## មាត្រា ១២

លើកលែងចំពោះសេចក្តីដូចមានចែងក្នុងមាត្រា ១១ គ្មានល័ក្ខខ័ណ្ឌណាមួយត្រូវបានដាក់ទៅលើអនុសញ្ញានេះបានឡើយ ។

## មាត្រា ១៣

១~ អនុសញ្ញានេះ គឺបើកចំហ ដើម្បីចុះហត្ថលេខានៅក្នុងទីក្រុង ម៉ុងរ៉េអាល់ កាលពីថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៩៩១ ដោយបណ្តារដ្ឋដែលបានចូលរួមក្នុងអង្គសន្និសីទអន្តរជាតិ ស្តីពីច្បាប់អាកាសដែលបានប្រារព្ធឡើងនៅទីក្រុង ម៉ុងរ៉េអាល់ ចាប់ពីថ្ងៃទី ១២ ខែ កុម្ភៈ ដល់ថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៩៩១ ។ បន្ទាប់ពីថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៩៩១ អនុសញ្ញានេះ គឺបើកចំហសំរាប់បណ្តារដ្ឋទាំងអស់ដើម្បីចុះហត្ថលេខា នៅទីស្នាក់ការនៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ក្នុងទីក្រុងម៉ុងរ៉េអាល់ រហូតអនុសញ្ញានេះចូលជាធរមាន ដោយអនុលោមតាមកថាខ័ណ្ឌ ៣ នៃមាត្រានេះ ។ រដ្ឋណាដែលមិនចុះហត្ថលេខាលើអនុសញ្ញានេះ អាចទទួលយល់ព្រមតាមអនុសញ្ញានេះនៅពេលណាក៏បាន ។

២~ អនុសញ្ញានេះត្រូវស្ថិតនៅក្រោមការផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬការយល់ព្រម ឬការសុំចូលជាសមាជិកពីបណ្តារដ្ឋ ។ លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិក ត្រូវដាក់ជូនអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដែលត្រូវបានជ្រើសរើសតាមរយៈគណៈកម្មការទទួលបន្ទុក ។ នៅពេលបញ្ជូនលិខិតុបករណ៍នៃការផ្តល់សច្ចាប័នរបស់ខ្លួន រដ្ឋនីមួយៗត្រូវប្រកាសថាជារដ្ឋមានផលិត ឬគ្មានផលិត ។

៣-អនុសញ្ញានេះត្រូវចូលជាធរមានហុកសិបថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនលិខិតុបករណ៍ ទីសាមសិបប្រាំនៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬសុំចូលជាសមាជិកជាមួយ គណៈកម្មការទទួលបន្ទុក ដោយ បញ្ជាក់ថាមានរដ្ឋមិនតិចជាងប្រាំ បានប្រកាសស្របតាមកថាខ័ណ្ឌ ២ នៃមាត្រានេះថាជារដ្ឋផលិត ។ ប្រសិនបើលិខិតុបករណ៍ចំនួនសាមសិបប្រាំ ដែលត្រូវបានបញ្ជូនមកមុនការបញ្ជូនលិខិតុបករណ៍ ពីរដ្ឋផលិតចំនួនប្រាំ អនុសញ្ញានេះត្រូវចូលជាធរមាន នៅថ្ងៃទីហុកសិប បន្ទាប់ពីថ្ងៃនៃការដាក់បញ្ជូនលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិកនៃរដ្ឋផលិតទីប្រាំ ។

៤-សំរាប់រដ្ឋផ្សេងៗទៀត អនុសញ្ញានេះត្រូវចូលជាធរមានហុកសិបថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់លិខិតុប-ករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិក ។

៥-នៅពេលដែលអនុសញ្ញានេះចូលជាធរមានភ្លាម អនុសញ្ញានេះត្រូវចុះបញ្ជីដោយគណៈកម្មការទទួលបន្ទុក អនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងអនុលោមតាមមាត្រា ៨៣ នៃអនុសញ្ញាស្តីពីអាកា-សចរណ៍ស៊ីវិលអន្តរជាតិ (Chicago , ១៩៤៤) ។

## មាត្រា ១៤

គណៈកម្មការទទួលបន្ទុកត្រូវផ្តល់ពត៌មានជាបន្ទាន់ដល់រដ្ឋហត្ថលេខី និងរដ្ឋភាគីទាំងអស់នូវៈ

១-ហត្ថលេខានីមួយៗនៃអនុសញ្ញានេះ និងកាលបរិច្ឆេទនៃអនុសញ្ញានេះ

២-រាល់ការបញ្ជូនលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិកនិងកាលបរិច្ឆេទនៃការសុំចូលត្រូវផ្តល់សេចក្តីបញ្ជាក់ពិសេសថា តើរដ្ឋនោះបានទទួលស្គាល់ថាខ្លួនជារដ្ឋផលិតដែរ ឬទេ ។

៣-កាលបរិច្ឆេទការចូលជាធរមាននៃអនុសញ្ញានេះ

៤-កាលបរិច្ឆេទការចូលជាធរមាន នូវរាល់ការធ្វើវិសោធនកម្មណាមួយនៃអនុសញ្ញានេះ ឬឧបសម្ព័ន្ធបច្ចេកទេសនៃអនុសញ្ញានេះ

៥- សេចក្តីប្រកាសមិនយល់ព្រមណាមួយបានធ្វើឡើងស្របតាមមាត្រា ១៥ និង

៦- សេចក្តីប្រកាសណាមួយបានធ្វើឡើងស្របតាមវាក្យខ័ណ្ឌ ២ នៃមាត្រា ១១

## មាត្រា ១៥

១-រដ្ឋភាគីមួយអាចប្រកាសមិនយល់ព្រមលើអនុសញ្ញានេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកគណៈកម្មការទទួលបន្ទុក

២-សេចក្តីប្រកាសមិនយល់ព្រមនឹងមានប្រសិទ្ធិភាពរយៈពេលមួយរយប៉ែតសិបថ្ងៃដោយគិតពីថ្ងៃដែលគណៈ

កម្មការទទួលបន្ទុកបានទទួលសេចក្ដីជូនដំណឹងនេះ ។

ដើម្បីជាសាក្សី បេសកជនវិសាមញ្ញ និងពេញសមត្ថភាព ជាតំណាងស្របច្បាប់ដែលតែងតាំងដោយ រដ្ឋាភិបាលនៃប្រទេសរបស់ខ្លួនបានចុះហត្ថលេខាលើអនុសញ្ញានេះ ។

ធ្វើនៅទីក្រុង ម៉ុងរេអាល់ ថ្ងៃទី មួយ ខែមិនា ឆ្នាំ មួយពាន់ប្រាំបួនរយកៅសិបមួយ អត្ថបទដើមត្រូវបានសរសេរជាប្រាំភាសាមានតម្លៃស្មើគ្នាគឺ អង់គ្លេស បារាំង រុស្ស៊ី អេស្ប៉ាញ៉ុល និងអារ៉ាប៊ី ។

# ឧបសម្ព័ន្ធ II

# ឧបសម្ព័ន្ធបច្ចេកទេស

## ភាគ ១

## ការពិពណ៌នាពីគ្រឿងផ្ទុះ

I- គ្រឿងផ្ទុះដែលចែងក្នុងកថាខ័ណ្ឌ ១ មាត្រា ១ នៃអនុសញ្ញានេះ គឺគ្រឿងផ្ទុះទាំងឡាយណាដែល :

ក- ត្រូវបានរៀបចំយ៉ាងជាក់លាក់ជាមួយនិងគ្រឿងផ្ទុះមួយ ឬច្រើនដែលទ្រង់ទ្រាយសុទ្ធនៃគ្រឿងផ្ទុះនោះ មានសម្ពាធចំហាយតិចជាង $10^{-4} p_a$ មានសីតុណ្ហភាព ២៥ អង្សាសេ។

ខ- ត្រូវបានរៀបចំយ៉ាងជាក់លាក់ជាមួយនិងសំភារៈភ្ជាប់ឱ្យនៅផ្តុំគ្នា ហើយនិង

គ- ជាគ្រឿងផ្ទុះចំរុះ ទន់ ឬអាចបត់បែនបានទៅតាមសីទណ្ហភាពនៅក្នុងបន្ទប់ធម្មតា។

II-គ្រឿងផ្ទុះទាំងឡាយនេះ ទោះបីជាកិច្ចប្រជុំបានពិពណ៌នាពីគ្រឿងផ្ទុះនេះ នៅក្នុងកថាខ័ណ្ឌ១ នៃភាគនេះ ក៏នឹងមិនត្រូវបានចាត់ទុកថា ជាគ្រឿងផ្ទុះដ៏រាបណាគ្រឿងផ្ទុះនោះត្រូវបានគេកាន់កាប់ ឬបន្តប្រើប្រាស់សំរាប់បំណងជាក់លាក់ដូចខាងក្រោម ឬនៅតែត្រូវបានធ្វើសាជីវកម្មយ៉ាងច្បាស់លាស់នោះពោលគឺ គ្រឿងផ្ទុះទាំងឡាយណាដែល :

ក-ត្រូវបានផលិតឡើង ឬរក្សាទុកក្នុងបរិមាណបានកំណត់ទុក សំរាប់ការប្រើប្រាស់ស្រាវជ្រាវស្របច្បាប់ ការអភិវឌ្ឍន៍ ការសាកល្បងគ្រឿងផ្ទុះថ្មី ឬគ្រឿងផ្ទុះកែច្នៃ ។

ខ-ត្រូវបានផលិតឡើង ឬរក្សាទុកក្នុងបរិវេណបានកំណត់ទុក សម្រាប់ប្រើប្រាស់ក្នុងការហ្វឹកហ្វឺនស្របច្បាប់ ដើម្បីការរកគ្រឿងផ្ទុះ ហើយនិង ឬការអភិវឌ្ឍន៍គ្រឿងផ្ទុះ ឬសាកល្បងនៃឧបករណ៍រកគ្រឿងផ្ទុះ ។

គ-ត្រូវបានផលិតឡើង ឬរក្សាទុកក្នុងបរិមាណបាកំណត់ទុក សំរាប់តែការប្រើប្រាស់ក្នុងគោលបំណង នៃនីតិវិទ្យាសាស្ត្រស្របច្បាប់ (Forensic Science purposes )

ឃ-ទុកសំរាប់ នឹងដែលត្រូវបានធ្វើសាជីវកម្មដែលជាផ្នែកទាំងស្រុង នៃឧបករណ៍យោធាស្របច្បាប់ក្នុងទឹកដីនៃរដ្ឋផលិត ក្នុងរយៈពេល ៣ ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន ចំពោះរដ្ឋនោះ ។ ឧបករណ៍នេះ ដែលបានផលិតឡើងក្នុងអំឡុងពេល ៣ឆ្នាំនោះ ត្រូវបានគេចាត់ទុកថា ជាឧបករណ៍យោធាស្របច្បាប់ ដូចមានចែងក្នុងកថាខ័ណ្ឌ ៤ មាត្រា ៤ នៃអនុសញ្ញានេះ ។

III- ក្នុងភាគនេះ

- ស្របច្បាប់ នៅកថាខ័ណ្ឌ ២ ក.ខ និង គមានន័យថា បានអនុញ្ញាតស្របតាមច្បាប់ និងបទបញ្ជា នៃរដ្ឋភាគីដែលជាប់ពាក់ព័ន្ធ ហើយនិង

- គ្រឿងផ្ទុះកំរិតខ្ពស់ ដែលមានទៅក្នុងនោះ ប៉ុន្តែមិនត្រូវកំណត់លើ Cyclotetramethylenetetramine (HMLX) pentaery thritol tettranitrate(PETN) ហើយនិង Cyclotrimethylenetetramine(RDX)

Honduras, the Repolic of
India, the Repolic of
Indonesia, the Repolic of
Iran,Islamic Repolic of
Israel, the State of
Italian Repolic the
Jamaica
Japan
Kenya, the Repolic of
Kuwait, the State of
Lebanese Republic the
Madagascar, the Democratic Republic of
Mali, the Repolic of
Mauritius
Mexican States, the United
Morocco, the Kingdom of
Netherlands, the Kingdom of the
Nigeria, the federal Republic of
Noeway, the Kingdom of
Pakistan, the Islamic Republic of
Paraguay, the Repolic of
Paru, the Repolic of
Poland, the Repolic of
Qatar, the state of
Republic of Korea, the
Romania
Saudi Arrabia, the Kingdom of
Senegal, the Repolic of
Spain, the Kingdom of
Sweden, the Kingdom of
Swiss Confederation, the
Thailand, the Kingdom of
Togolese Republic, the
Trinidad and Tobago, the Repolic of
Tunisia, the Repolic of
Turkey, the Repolic of
Uganda, the Repolic of
Ukrainian Soviet Socailist republic, the
Union of Soviet Socailist republic, the
United Arab Emerates, the
United Kingdom of Great Britain and northern Ireland, the
United Republic of Tanzania, the
United States of America, the
Venezuela, the public of
Zaire, the public of
Zambia, the Republic of

អង្គការអន្តរជាតិខាងក្រោមត្រូវបានធ្វើជាអ្នកតំណាងសង្កេតការណ៍

១- អង្គការសហប្រជាជាតិ ( UN )

២- អង្គការដែនសមុទ្រ ( IMO )

៣- សហគមន៍ដឹកជញ្ជូនផ្លូវអាកាសអន្តរជាតិ ( IAIA)

៤- សហគមន៍អន្តរជាតិ នៃសហគមន៍ក្រុមហ៊ុនអាកាសចរណ៍ PILOT.(IFAPA )

៥- គណៈកម្មការអាកាសចរណ៍ស៊ីវិលអាហ្វ្រិក ( AFCAC )

៦- គណៈកម្មការអាកាសចរណ៍ស៊ីវិលអាមេរិកឡាទីន ( LACAC )

សន្និសីទនេះត្រូវបានប្រកាសបើក និងថ្លែងការណ៍ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិលោក Javer Perez de Cuella ហើយនិងប្រធានក្រុមប្រឹក្សាអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ Dr Assad Kotaite ។

សន្និសីទបានបោះឆ្នោតជ្រើសរើស Dr. K.O. Rattray "ប្រទេស Jamaica" ជាប្រធាន Dr.F.A.Cede "ប្រទេស "Austria "Dr.H.A. Perucchi"ប្រទេស"Agentina " លោក M. Mukai " ប្រទេស Jampan " លោក V.Poonoosamy " ប្រទេស Mauritius " ជាអនុប្រធាន ។

អគ្គលេខាធិការនៃសន្និសីទនេះគឺ Dr.S.S Sidhu អគ្គលេខាធិការនៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ។ Dr.Milde នាយកការិយាល័យច្បាប់នៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ជាលេខាធិការប្រតិបត្តិនៃសន្និសីទនេះ លោកត្រូវបានជួយជ្រោមជ្រែងដោយ Dr . M . Poucelet មន្ត្រីគោលការណ៍ច្បាប់ លោក R.K. VanDam មន្ត្រីច្បាប់ជាន់ខ្ពស់ លោក G. M. Rakar និងលោក J. V. Augustin មន្ត្រីច្បាប់នៃអង្គការនេះ ហើយនិងមន្ត្រីផ្សេង១ទៀត នៃអង្គការនេះ ។

សន្និសីទនេះ បានបង្កើតគណៈកម្មាធិការមួយដែលប្រធានរបស់វា ជាប្រធានសន្និសីទនេះ ហើយនិងបានបង្កើតគណៈកម្មាធិការដូចខាងក្រោមនេះ :

គណៈកម្មាធិការសារតាំង

-ប្រធាន : Dr. L. Jakubovice (ប្រទេសប្រេស៊ិល )

-សមាជិក: ប្រទេសឆេកូស្លូវ៉ាគី ហ្គាណា លីបង់ ស៊ុយអែត

គណៈកម្មាធិការព្រាងច្បាប់

-ប្រធាន : លោក M. V. Poonoosamy (ប្រទេស Mauritius)

-សមាជិ : ប្រទេស
- -Agentina
- -Canada
- -China
- -Côte d'Ivoire
- -Czechoslvakia
- -Egypt
- -France
- -Islamic Republic of Iran
- -Japan
- -Pakistan
- -Saudi Arabia

-Union of Soviet Socialist Republic
-United Kingdom
-United states
-Venezuela

បន្ទាប់ពីពិភាក្សាសន្និសីទនេះ បានអនុវត្តដោយមតិកុងសង់ស៊ីស លើអត្ថបទអនុសញ្ញាមួយស្តីពីការកត់សំគាល់គ្រឿងផ្ទុះសំរាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក ។ អនុសញ្ញាដែលបានថ្លែងខាងលើនេះត្រូវបានបើកចំហឱ្យចុះហត្ថលេខានៅទីក្រុងម៉ុងរេអាល់នៅថ្ងៃនេះ ម្យ៉ាងទៀតសន្និសីទបានអនុវត្តតាមមតិកុងសង់ស៊ីសលើសេចក្តីដូចខាងក្រោម :

-ដោយហេតុថា មានអំពើខុសច្បាប់ប្រឆាំង ទៅនឹងអាកាសចរណ៍ស៊ីវិល នាវាចរ ហើយនិងវិធីផ្សេង១ទៀត នៃការដឹកជញ្ជូនបានជាប់ទាក់ទិន្ទជាញឹកញាប់ទៅនឹងការប្រើប្រាស់គ្រឿងផ្ទុះ និងសំភារៈគ្រឿងផ្ទុះ ឬ

-ដោយហេតុថា ការកំណត់សំគាល់គ្រឿងផ្ទុះឬស៊ីកសំរាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក និងជួយឱ្យរដ្ឋទប់ស្កាត់អំពើបែបនេះ

-ដោយសំគាល់ថា សារសំខាន់ចំពោះរដ្ឋទាំងអស់អាចរកមធ្យោបាយសមរម្យដល់ការរកឱ្យឃើញនេះ

-ដោយទទួលស្គាល់ថា ការអនុវត្តន៍មធ្យោបាយបែបនេះអាចបណ្តាលឱ្យមានការលំបាកចំពោះរដ្ឋខ្លះនោះ

-ដោយយល់ឃើញចំពោះបំណងប្រាថ្នានៃកិច្ចការបន្ថែម ដែលទាក់ទងក្នុងការរកឃើញគ្រឿងផ្ទុះ ក្រៅអំពីគ្រឿងផ្ទុះឬស៊ីកដែលអាចត្រូវបានប្រើប្រាស់សំរាប់អំពើខុសច្បាប់នោះ ។

-ដោយកត់សំគាល់ថា មានការចាប់អារម្មណ៍ជាបន្តបន្ទាប់របស់អង្គការសហប្រជាជាតិ និងជាពិសេសរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ហើយនិងអង្គការដែនសមុទ្រអន្តរជាតិនោះ សន្និសីទ :

១-ជំរុញរដ្ឋឱ្យក្លាយជាភាគី ចំពោះអនុសញ្ញាស្តីអំពីការកត់សំគាល់គ្រឿងផ្ទុះឬស៊ីក សំរាប់បំណងការរកឃើញឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។

២-អំពាវនាវរដ្ឋដែលផលិតគ្រឿងផ្ទុះឬស៊ីក ឱ្យអនុវត្តការកត់សំគាល់គ្រឿងផ្ទុះបែបនេះឱ្យបានឆាប់បំផុត ។

៣-ស្នើរដ្ឋទាំងឡាយឱ្យបន្តជំរុញលើកទឹកចិត្តធ្វើការស្រាវជ្រាវ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យប្រសើរ និងតាមមធ្យោបាយសេដ្ឋកិច្ចនៃការរុករកឱ្យឃើញទាំងអស់នូវភ្នាក់ងារកត់សំគាល់ ដែលបានបញ្ជាក់ច្បាស់លាស់នៅក្នុងអនុសញ្ញានេះ ។

៤-ជំរុញសហគមន៍អន្តរជាតិ ឱ្យពិចារណាបង្កើននូវជំនួយបច្ចេកទេសហិរញ្ញវត្ថុ និងសំភារៈដល់រដ្ឋដែលត្រូវការជំនួយបែបនេះ ដើម្បីអាចទទួលយកប្រយោជន៍ពីស្នាដៃនៃបំណង និងគោលដៅ ក្នុងអនុសញ្ញានេះ ជាពិសេសតាមរយៈកម្មវិធីជំនួយបច្ចេកទេស នៃអង្គការអាកាសចរណ៍ស៊ីវិលអន្តជាតិ ។

៥-អញ្ជើញក្រុមប្រឹក្សានៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិដើម្បី :

ក- ទទួលកាន់កាប់តំណែងដែលបានចែងក្នុងអនុសញ្ញានេះ

ខ-រក្សាទុកនូវអត្ថិភាពក្រុម Ad Hoc ដែលមានស្រាប់នូវជំនាញខាងការរកឃើញគ្រឿងផ្ទុះ ដើម្បីជួយឱ្យអ្នកជំនាញនេះបន្តការសិក្សា ដែលអាចរក្សាឧប្បសម្ព័ន្ធបច្ចេកទេសចំពោះអនុសញ្ញាឱ្យបានទំនើប ដោយរង់ចាំចូលជាធរមាន

នៃអនុសញ្ញានេះ និងបង្កើតគណៈកម្មការបច្ចេកទេសគ្រឿងផ្ទុះអន្តរជាតិ

គ-គោរពគោលការណ៍នៃការតំណាងភូមិសាស្ត្រ សមធម៌ ក្នុងការតែងតាំងសមាជិក នៃគណៈកម្មការបច្ចេកទេសគ្រឿងផ្ទុះអន្តរជាតិ

៦-ស្នើសុំអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដើម្បីផ្តួចផ្តើមគំនិតសិក្សាក្នុងវិធីសាស្ត្រ នៃការរកឃើញគ្រឿងផ្ទុះ និងសំភារៈគ្រឿងផ្ទុះ ជាបញ្ហាដែលមានអទិភាពខ្ពស់ ជាពិសេសក្នុងការកត់សំគាល់គ្រឿងផ្ទុះទាំងនោះ ក្រៅអំពីគ្រឿងផ្ទុះប្លាស្ទិកដែលគេបានរកឃើញវា ដោយបានជំនួយដោយការប្រើប្រាស់ភ្នាក់ងារសំគាល់ បើសិនជាត្រូវការចាំបាច់ ដោយតាមការវិវឌ្ឍន៍ច្បាប់ដ៏ទូលំទូលាយដ៏សមស្របមួយ ។

ដើម្បីជាសាក្សី ប្រតិភូនៃរដ្ឋស្របច្បាប់ បានចុះហត្ថលេខាលើសេចក្តីសំរេចចិត្តចុងក្រោយនេះ ។

ធ្វើនៅទីក្រុងម៉ុងរេអាល់ ថ្ងៃទីមួយ ខែមីនា ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបមួយ អត្ថបទប្រាំច្បាប់មានតំលៃស្មើគ្នា សរសេរប្រាំភាសាមាន អង់គ្លេស បារាំង រុស្ស៊ី អេស្ប៉ាញ៉ុល ហើយនិង អារ៉ាប៊ីក ។

ច្បាប់ថតចំលងមួយច្បាប់ ត្រូវបានដាក់ជូនជាមួយអង្គការអាកាសចរស៊ីវិលអន្តរជាតិ ហើយច្បាប់ថតចំលងដ៏ជាក់លាក់មួយនៃច្បាប់ថតចំនងនេះត្រូវបានផ្ញើរជូនដោយអង្គការខាងលើនេះ ទៅឱ្យរដ្ឋាភិបាលនីមួយៗ ដែលជាតំណាងនៅឯសន្និសីទនេះ ។

## ភាគ២

## សារធាតុភ្នាក់ងាររុករក

-សារធាតុភ្នាក់ងាររុករកគឺ ជាសារធាតុមួយនៃសារធាតុទាំងឡាយ ដែលបានចែងក្នុងតារាងខាងក្រោមនេះ សារធាតុភ្នាក់ងាររុករកដែលបានពិពណ៌នានៅក្នុងតារាងនេះ គឺក្នុងគោលបំណងឱ្យប្រើប្រាស់ដើម្បីលើកស្ទួយសមត្ថភាពរុករកឱ្យឃើញគ្រឿងផ្ទុះ តាមមធ្យោបាយប្រើប្រាស់ការរកឃើញចំហាយ ។ ក្នុងករណីនីមួយៗការដាក់បញ្ចូលសារធាតុភ្នាក់ងាររុករកទៅក្នុងគ្រឿងផ្ទុះនេះ នឹងត្រូវបានធ្វើឡើងក្នុងលក្ខណៈបែបណាមួយ ដើម្បីឱ្យរលាយចូលសាច់មួយស្មើដៃគ្នា ក្នុងផលិតផលបញ្ចប់ ។

នៅពេលផលិត ការប្រមូលផ្តុំអប្បបរមានៃសារធាតុភ្នាក់ងាររុករក ក្នុងផលិតផលបញ្ចប់ ការផលិតនឹងត្រូវបានបង្ហាញនៅក្នុងតារាងដូចខាងក្រោម :

**តារាង១**

| ឈ្មោះសារធាតុភ្នាក់ងាររុករក | រូបមន្ត Molecular | ទំងន់ Molecular | ការប្រមូលផ្តុំអប្បបរមា |
|---|---|---|---|
| Ethrylene glycol-dinitrate(EGDN) | C2H4(NO1)2 | 152 | 0.2% by mass |
| 2,3Dimethy 1-2-3 dinitrobutan (DMNB) | C6G12(NO2)2 | 176 | 0.1% by mass |
| Para-mononitroluen (P-MNT) | C7H7NO2 | 137 | 0.5% by mass |
| Otho-mononitrotoluene (O-MNT) | C7H7NO2 | 137 | 0.5% by mass |

**មាត្រា ១:** តែងតាំងឯកឧត្តម នូ ទេពីរិទ្ធ ជាទីប្រឹក្សាសម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកផ្នែកនីតិកម្ម មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ៤០៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

៣កល-០៥១០.៤៦០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

# ព្រះរាជក្រឹត្យ

នស/រកត/១០០៥/៨៣៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងលោកជំទាវ សំ នារី ជាជំនួយការសម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៤០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ង៉ី តាន់

៣រស-០៥១០-៤៦១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

# ព្រះរាជក្រឹត្យ

នស/រកត/១០០៥/៤៣៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គល សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា)

**តែងតាំង**

លោក **ឈន សារ៉ាំណែ**

ជា

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤ល-០៥១០-៤៦៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

លេខៈ ៥០៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ ១០ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៥/៤៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនវរសេនីយ៍ឯក **សំ បូរ** អត្តលេខ ០៩៥៣ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ : ៤០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន តាន់

ពរល.០៥១០.៤២៣

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

# ព្រះរាជក្រឹត្យ

នស/រកត/១០០៥/៨៣៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងឯកឧត្តម **ស៊ាន វិសុទ្ធ** ឧត្តមមន្ត្រីថ្នាក់លេខ២ ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើរដ្ឋលេខាធិការ ។

**មាត្រា២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជ-ក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល-០៥១០.៨៦៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

លេខ ៤៨៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ១០ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សំណាង តាន់**

tito 07-05-2005 2.doc

នស/រកត/១០០៥/៤៣៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ

ចំពោះ

សពឯកឧត្តម **អ៊ី គីហ៊ាង**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល-០៤១០.៤៦៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

លេខៈ ៥០៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ១៧ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាឌី តាន់**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧០ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ. បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ . បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១ :** ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលចំណុះផ្ទាល់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២ :** នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង

សហប្រតិបត្តិការអន្តរជាតិ

ហោ ណាំហុង

**កន្លែងទទួល:**

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

អគ្គលេខាធិការរាជរដ្ឋាភិបាល

ដូចមាត្រា ៤

ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២១ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រី រាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៦

# រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ សេចក្តីសំរេចរបស់ក្រុមប្រឹក្សារាជសម្បត្តិ លេខ គរស/សសរ/១០០៤/០០១ ចុះថ្ងៃ ១៤ ខែតុលា ឆ្នាំ ២០០៤ ស្តីពីការជ្រើសរើសព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

# ស ម្រេ ច

**មាត្រា ១.-**

អនុញ្ញាតអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ បានឈប់សម្រាកការងារប្រចាំឆ្នាំ ២០០៦ តាមប្រតិទិន ដូចខាងក្រោម :

| | | | |
|---|---|---|---|
| - ថ្ងៃទី ០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ | មករា | ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៣ | កុម្ភៈ | ពិធីបុណ្យមាឃបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៨ | មីនា | ទិវានារីអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៤-១៥-១៦ | មេសា | ពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

| | | | |
|---|---|---|---|
| - ថ្ងៃទី ១២ | ឧសភា | ពិធីបុណ្យវិសាខបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៣-១៤-១៥ | ឧសភា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ១៦ | ឧសភា | ព្រះរាជពិធីបុណ្យច្រត់ព្រះន័ង្គល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៨ | មិថុនា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតា **នរោត្តម មុនិនាថ សីហនុ** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២១-២២-២៣ | កញ្ញា | ពិធីបុណ្យភ្ជុំបិណ្ឌ | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៩ | តុលា | ព្រះរាជពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ៣១ | តុលា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះវររាជបិតា ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៤-០៥-០៦ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុក | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ០៩ | វិច្ឆិកា | ពិធីបុណ្យឯករាជ្យជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១០ | ធ្នូ | ទិវាសិទ្ធិមនុស្សអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

**មាត្រា ២.-**

ពេលវេលាឈប់សម្រាកទាំងឡាយណាដែលត្រូវចំថ្ងៃណាមួយនៃថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍ (សៅរ៍ ឬ អាទិត្យ) ត្រូវបានអោយឈប់ចំនួន ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែ ក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវអនុញ្ញាតអោយឈប់សម្រាកបន្ថែមជំនួស គឺឈប់តែ ០១ ថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ....១២៨១....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាជិកជ្រើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិ សំរាប់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ អាណត្តិទី២ លើកទី២

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០០៥ ស្តីពីការកែប្រែមាត្រា២ នៃអនុក្រឹត្យ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីរបៀបរបបនិងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម

-បានឃើញកំណត់ហេតុ ស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មរាជធានីភ្នំពេញ កាលពីថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ២០០៥ និងថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០៥

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ស ម្រេ ច

**មាត្រា ១.-**

ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ចំនួន ៤០រូប ដែលបែងចែកតាមប្រភេទអាជីវកម្ម ដូចខាងក្រោម ÷

**<u>ប្រភេទ ពាណិជ្ជកម្ម</u>**

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១-អ្នកឧកញ៉ា | គិត | ម៉េង | ៥- ឧកញ៉ា | ភុក | អាន | ៩- ឧកញ៉ា | តែ | តាំងប៉ះ |
| ២-អ្នកឧកញ៉ា | សុខ | គង់ | ៦- ឧកញ៉ា | ស៊ីវ | ផៃ | ១០-លោក | ហ៊ី | ហេង |
| ៣-អ្នកឧកញ៉ា | គង់ | ទ្រីវ | ៧- ឧកញ៉ា | គិត | ឌៀង | ១១-លោក | ហោ | ម៉េន |
| ៤- ឧកញ៉ា | លី | យ៉ុងផាត់ | ៨- ឧកញ៉ា | លឹម | ប៊ុនសួរ | ១២-លោក | ទី | ឃួរ |

**<u>ប្រភេទ ឧស្សាហកម្ម និង សិប្បកម្ម</u>**

| | | | | | |
|---|---|---|---|---|---|
| ១- ឧកញ៉ា | ស៊ន | សុខណា | ៧-លោក | តាំង | ម៉េងហ៊ុយ |
| ២- ឧកញ៉ា | ហាន់ | ឃាង | ៨- ជំទាវឧកញ៉ា | កែវ | ម៉ាលី |
| ៣- ឧកញ៉ា | ឡូច | សារ៉េត | ៩-លោក | គង់ | សាង |
| ៤- ឧកញ៉ា | សូ | ខូន | ១០- ឧកញ៉ា | ហ៊ុន | បានឃួរ |
| ៥-លោកស្រីឧកញ៉ា | ចាន់ | សុឌ្ឋា | ១១-លោក | ទ៉ាន់ | ស៊ូអៀង |
| ៦- ឧកញ៉ា | ផៃ | ហុកឈួន | ១២-លោកស្រី | ជុង | ចាន់សោភា |

**<u>ប្រភេទ សេវាកម្ម និង វិជ្ជាជីវៈសេរី</u>**

| | | | | | |
|---|---|---|---|---|---|
| ១- ឧកញ៉ា | ឡាវ | ម៉េងឃីន | ៦-លោក | ថៃ | អ៊ុយ |
| ២- ឧកញ៉ា | ធី | ពិសិដ្ឋ | ៧-លោក | វិញ | ឃួ |
| ៣- ឧកញ៉ា | ស៊ិន | សុខា | ៨-លោក | គុជ | ស៊ីនិត |
| ៤- ឧកញ៉ា | យ៉ាំ | ស៊ុយសាំង | ៩-លោក | ខេន | សុភា |
| ៥-លោកជំទាវ | លឹម | ឈីវឃួរ | ១០-លោក | ឡាយ | ប៊ុនចាំ |

**<u>ប្រភេទ កសិកម្ម</u>**

| | | | | | |
|---|---|---|---|---|---|
| ១- ឧកញ៉ា | ម៉ែន | សារុន | ៤-លោក | លី | គួយ |
| ២- ឧកញ៉ា | ម៉ុង | ឫទ្ធី | ៥-លោក | ជា | រតនា |
| ៣-លោក | ណាង | សុធី | ៦-លោកស្រី | ទ៉ូវ | ម៉ុក |

**មាត្រា ២.-**

ទទួលស្គាល់អ្នកឧកញ៉ា គិត ម៉េង ជាប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ។

**មាត្រា ៣.-**

ទទួលស្គាល់អ្នកឧកញ៉ា សុខ គង់ ជាប្រធានកិត្តិយសសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ។

**មាត្រា ៤.-**

ទទួលស្គាល់ការបង្កើតការិយាល័យប្រតិបត្តិមួយរបស់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ÷

១-អ្នកឧកញ៉ា គិត ម៉េង ជាប្រធាន

| | | | |
|---|---|---|---|
| ២-ឧកញ៉ា | គង់ | ទ្រីវ | ជាអនុប្រធាន |
| ៣-អ្នកឧកញ៉ា | ម៉ែន | សារុន | ជាអនុប្រធាន |
| ៤-ឧកញ៉ា | លី | យ៉ុងផាត់ | ជាអនុប្រធាន |
| ៥-ឧកញ៉ា | ភុក | អាន | ជាអនុប្រធាន |
| ៦-ឧកញ៉ា | សឺន | សុខណា | ជាអនុប្រធាន |
| ៧-ឧកញ៉ា | ហាន់ | ឃាង | ជាអនុប្រធាន |
| ៨-ឧកញ៉ា | ម៉ុង | រិទ្ធី | ជាអនុប្រធាន |
| ៩-ឧកញ៉ា | ឡាវ | ម៉េងឃីន | ជាអនុប្រធាន |
| ១០-ឧកញ៉ា | យ៉ាំ | ស៊ុយសាំង | ជាអនុប្រធាន |
| ១១-ជំទាវឧកញ៉ា | លឹម | ឈីវហួរ | ជាអនុប្រធាន |
| ១២-ឧកញ៉ា | គិត | ឆៀង | ជាហិរញ្ញិក |
| ១៣-ឧកញ៉ា | ស៊ីវ | ង៉ៃ | ជាហិរញ្ញិករងទី ១ |
| ១៤-លោកស្រីឧកញ៉ា | ចាន់ | សុឆ្លា | ជាហិរញ្ញិករងទី ២ |
| ១៥-ឧកញ៉ា | សូ | ខួន | ជាហិរញ្ញិករងទី ៣ |
| ១៦-លោក | ណរាង | សុធី | ជាលេខាទី ១ |
| ១៧-ឧកញ៉ា | តែ | តាំងប៉ោ | ជាលេខាទី ២ |
| ១៨-ឧកញ៉ា | ស៊ិន | សុខា | ជាលេខាទី ៣ |

**មាត្រា ៥.-**

បទប្បញ្ញត្តិ ទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ មាត្រា២ មាត្រា៣ និងមាត្រា៤ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ...១២៥៧...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា១.-** ត្រូវបានលុបឈ្មោះលោកស្រី **ឆាន លីហួ** វរមន្ត្រីថ្នាក់លេខ ៦ អគ្គនាយករងរដ្ឋបាល-ហិរញ្ញវត្ថុ ពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងអភិវឌ្ឍន៍ជនបទ ដោយមូលហេតុមរណភាព ។

**មាត្រា២.-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ...៧ ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- កាលប្បវត្តិ-ឯកសារ

Chantha004 Anoukrit

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩៤៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
៛៣៛
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក វរសេនីយ៍ឯក **អានីល ខេ អាហ៊ុយ៉ា** (**Colonel Anil K Ahuya**) អនុព័ន្ធយោធា នៃសាធារណរដ្ឋឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងការលើកស្ទួយទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៩៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរក្របខ័ណ្ឌនាយទាហានពីកងយោធពលខេមរភូមិន្ទ អោយមកបំរើការងារនៅក្នុងក្របខ័ណ្ឌ មន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .-**

ត្រូវបានផ្ទេរក្រខ័ណ្ឌលោកវរសេនីយ៍ឯក **វុន វិឡូទាសនា** ពីក្របខ័ណ្ឌ កងយោធពលខេមរភូមិន្ទ នៃក្រសួងការពារជាតិ អោយមកបំរើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង - ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧១៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងថ្នាក់ជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- យោងសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតម្លើងថ្នាក់ ក្នុងឋានន្តរស័ក្តិ វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៥ ជូនមន្ត្រីរាជការ ចំនួន ០៨ រូប ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១ - លោក ចែម ឧត្តរិការ | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅជា វរមន្ត្រី ថ្នាក់លេខ ៣ |
| ២ - លោក រុយ ឈុនលី | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅជា វរមន្ត្រី ថ្នាក់លេខ ៣ |
| ៣ - លោក ឯក សុនចាន់ | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅជា វរមន្ត្រី ថ្នាក់លេខ ៤ |
| ៤ - លោក ញិក គីមឈុន | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅជា វរមន្ត្រី ថ្នាក់លេខ ៥ |
| ៥ - លោក សៀ និយម | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅជា វរមន្ត្រី ថ្នាក់លេខ ៥ |
| ៦ - លោក ចាន់ ចំរើន | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅជា វរមន្ត្រី ថ្នាក់លេខ ៨ |
| ៧ - លោក សុខ វ៉ាហ្វ៊ែរ | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅជា វរមន្ត្រី ថ្នាក់លេខ ៩ |
| ៨ - លោក ទ៉ៃ នាយលាង | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅជា វរមន្ត្រី ថ្នាក់លេខ ៩ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី " ដើម្បីជូនជ្រាប "
- ដូចមាត្រា ៣ " ដើម្បីអនុវត្ត "
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :......៤២.....ស.សរ

## សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅចូលរួមពិធីបើកពិពណ៌ ចិន-អាស៊ាន លើកទី២ នៅទីក្រុងណាន់និញនៃសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ២

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៧៨១ ឧរថ.កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៧៣/០៥ គ.វ.ក ចុះថ្ងៃទី១៥.០២.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ១៦១៥/០៥ គ.វ.ក ចុះថ្ងៃទី២០.០៥.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អ៊ីសធើន សាន់ ថឹបែ៊កខូ ចុះថ្ងៃទី២៥.០៨.២០០៥

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីសធើន សាន់ ថឹបែ៊កខូ (EASTERN SUN TOBACCO CO., LTD.) តំណាងដោយលោក LIN QIN-MO សញ្ជាតិចិន(តៃវ៉ាន់) អាយុ៤៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 130273979 ចុះថ្ងៃទី១៩.១០.២០០១ បង្កើតរោងចក្រ "ផលិតបារី" ដែលមានឈ្មោះថា "អ៊ីសធើន សាន់ ថឹបែ៊កខូ (EASTERN SUN TOBACCO)" មានទីតាំងស្ថិតនៅ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់អាគារ មកក្រសួងក្នុងរយៈពេល ៣ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតថាំ" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឹងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះចំណុចប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន អ៊ីសធើន សាន់ ឌីបែកខ្ញុ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកណ្តាល
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៥៤ ឧ.រ.ក/ប្រក

រាជធានីភ្នំពេញ. ថ្ងៃទី ១៩ ខែ ៧ ឆ្នាំ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស/ រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៣៩២/០៥ គ.វ.ក ចុះថ្ងៃទី២៩.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន រេនបូ ស្គ្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី០៦.០៦.២០០៥

# សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន រេនបូ ស្គ្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី (RAINBOW SCREEN PRINTING PTE LTD.) តំណាងដោយ លោក ANG BOON CHEOW. EDWARD សញ្ជាតិសិង្ហបុរី ភេទប្រុស អាយុ៤៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ S1205391F ចុះថ្ងៃទី២៩.០៤.១៩៩៧ បង្កើតរោងចក្រ "បោះពុម្ពសម្លៀកបំពាក់" ដែលមានឈ្មោះថា "រេនបូ ស្គ្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី (RAINBOW SCREEN PRINTING PTE LTD.)" មានទីតាំងស្ថិតនៅ ផ្លូវចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

<u>ប្រការ២</u>: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៣</u>: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ“បោះពុម្ពសម្លៀកបំពាក់” ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៤</u>: ក្រុមហ៊ុនត្រូវលើកបង្ហាញ “ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

<u>ប្រការ៥</u>: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៦</u>: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

<u>ប្រការ៧</u> : ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

<u>ប្រការ៨</u>: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

<u>ប្រការ៩</u>: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន រេនបូ ស្ព្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

<u>ប្រការ១០</u>: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

<u>ចម្លងជូន</u> :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
“ ដើម្បីជូនជ្រាប ”
- ដូចប្រការ ៩ “ ដើម្បីអនុវត្ត”
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ : ០២១/ ប្រ-ក /២០០៥

រាជធានីភ្នំពេញ. ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥

# ប្រកាស

## ស្តីពីការចេញប័ណ្ណអាវុធជន្លី ក្នុងកងយោធពលខេមរភូមិន្ទ

*****

## សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥ ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០០៥ ប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យ ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយនិងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

- យោងប្រកាសអន្តរក្រសួង លេខ ០០១/២០០៥ ប្រ.ក ចុះថ្ងៃទី ០៩ ខែមិនា ឆ្នាំ ២០០៥ ស្តីពីការកែតម្រូវប្រកាសអន្តរក្រសួងមហាផ្ទៃ-ក្រសួងការពារជាតិ លេខ ៧៩២ ប្រ.ក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៩៩
- បានឃើញសេចក្តីសំរេចលេខ ០៤២/០៤ ស.ស.រ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការចេញប័ណ្ណអាវុធខ្លី ផ្លាកលេខសំគាល់សំភារៈសឹក ប័ណ្ណបើកបរ ប័ណ្ណសំគាល់ និងផ្លាកលេខយានយន្តគ្រប់ប្រភេទរបស់ក្រសួងការពារជាតិ ។
- ដើម្បីធានាដល់ការគ្រប់គ្រងអាវុធខ្លីគ្រប់ប្រភេទក្នុងកងយោធពលខេមរភូមិន្ទ អោយមានសណ្តាប់ធ្នាប់របៀបរៀបរយនិងការប្រើប្រាស់បានត្រឹមត្រូវតាមច្បាប់កំណត់ ។

## សម្រេច

### ប្រការ ១ : កំណត់ទូទៅ

១.១- ប័ណ្ណអាវុធខ្លីរបស់កងយោធពលខេមរភូមិន្ទ ដែលបានចេញឱ្យប្រើប្រាស់កន្លងមក ដោយអត្ថបញ្ហាការប្តូរមកប្រើប្រាស់ប័ណ្ណអាវុធខ្លីថ្មី ។

១.២- អាវុធខ្លីគ្រប់ប្រភេទ ត្រូវបានផ្តល់ប័ណ្ណប្រើប្រាស់ គឺជាអាវុធខ្លី ដែលជាទ្រព្យសម្បត្តិរបស់កងយោធពលខេមរភូមិន្ទ ហើយត្រូវបានបំពាក់ និងចុះបញ្ជីគ្រប់គ្រងដោយក្រសួងការពារជាតិ ។

១.៣- អាវុធខ្លី ដែលត្រូវបានផ្តល់ប័ណ្ណប្រើប្រាស់របស់កងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ប្រភេទដូចខាងក្រោម :

- ប្រភេទទី ១ : អាវុធខ្លីប្រើប្រាស់ផ្ទាល់ខ្លួន
- ប្រភេទទី ២ : អាវុធខ្លីប្រើប្រាស់ក្នុងពេលប្រតិបត្តិការ ឬ បេសកកម្ម (រួម)

### ប្រការ ២ : រូបភាពប័ណ្ណអាវុធខ្លី :

២.១-ប័ណ្ណអាវុធខ្លី (ផ្ទាល់ខ្លួន) មានរាងបួនជ្រុងទ្រវែង ពីមុខមានពណ៌ផ្កាឈូក មានផ្កាភ្ញីព័ទ្ធជុំវិញមានសរសេរជាអក្សរខ្មែរ រូបសញ្ញាក្រសួងការពារជាតិ នៅខាងលើផ្នែកខាងស្តាំ ខាងក្រោមរូបសញ្ញា មានកន្លែងបិទរូបថត ២x៣ ( រូបថតអ្នកប្រើប្រាស់អាវុធខ្លី ) និងពីជ្រុងម្ខាងទៅជ្រុងម្ខាង មានរូបទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ផ្នែកខាងក្រោយប័ណ្ណ មានពណ៌ផ្កាឈូកព័ទ្ធជុំវិញទៅដោយគំនូសពណ៌ក្រហម មានសរសេរជាអក្សរខ្មែរ ។

២.២- ប័ណ្ណអាវុធខ្លី (រួម) មានរាងបួនជ្រុងទ្រវែង ពីមុខមានពណ៌បៃតង មានផ្កាភ្ញីព័ទ្ធជុំវិញមានសរសេរជាអក្សរខ្មែរ រូបសញ្ញាក្រសួងការពារជាតិនៅខាងលើផ្នែកខាងស្តាំ និងពីជ្រុងម្ខាងទៅជ្រុងម្ខាង មានរូបទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ ផ្នែកខាងក្រោយប័ណ្ណ មានពណ៌បៃតងព័ទ្ធជុំវិញដោយគំនូសពណ៌ទឹកប៊ិច មានសរសេរជាអក្សរខ្មែរ ។

២.៣- ប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់អាវុធខ្លី មានបញ្ជាក់អំពីប្រភេទអាវុធ លេខអាវុធ ចំនួនគ្រាប់ និងលក្ខខ័ណ្ឌដែលត្រូវគោរព ។

**ប្រការ ៣ : លក្ខខ័ណ្ឌប្រើប្រាស់**

៣.១- ការចេញប័ណ្ណ និងអនុញ្ញាតអោយប្រើប្រាស់ប័ណ្ណអាវុធខ្លី ចំពោះតែអាវុធខ្លីដូចដែលបានកំណត់ក្នុងប្រការ ១ ។

៣.២- គ្រប់ស្ថាប័នកងឯកភាពត្រូវបំពេញបែបបទ ដើម្បីស្នើសុំប័ណ្ណអាវុធខ្លី តាមឋានានុក្រម និងតាមការណែនាំ របស់សមត្ថកិច្ចជំនាញទទួលបន្ទុក ដោយមានភ្ជាប់មកជាមួយនូវបញ្ជីរៀបរាប់លំអិត អំពីបរិមាណ គុណភាព និងប្រភពបំពាក់អោយបានច្បាស់លាស់ ។

៣.៣- ចំពោះអាវុធខ្លីដែលខូចខាតមិនអាចប្រើប្រាស់បាន ដែលស្ថិតនៅក្នុងបញ្ជីគ្រប់គ្រង និងពុំទាន់មានសេចក្តីសំរេចថ្នាក់លើកាត់ចេញពីបញ្ជីគ្រប់គ្រង គឺត្រូវបានរក្សាទុកក្នុងបញ្ជី និងបញ្ចូលក្នុងស្ថិតិដែលត្រូវស្នើសុំប័ណ្ណប្រើប្រាស់ថ្មី រហូតដល់ពេលមានសេចក្តីសំរេចពីក្រសួងការពារជាតិ ។

- ចំពោះអាវុធខ្លីដែលធ្វើការផ្លាស់ប្តូរគ្រឿងបន្លាស់ ឬ ធ្វើអោយបាត់ប័ណ្ណអាវុធថ្មីនេះ ត្រូវធ្វើបែបបទដើម្បីសុំកែសំរួលប័ណ្ណថ្មីទៀត សំរាប់ប្រើប្រាស់អោយបានត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់អាវុធខ្លី ។

- អាវុធខ្លីរបស់កងយោធពលខេមរភូមិន្ទជាមធ្យោបាយយកតាមខ្លួន និងការពារសុវត្ថិភាព សន្តិសុខផ្ទាល់ខ្លួនក្នុងពេលប្រតិបត្តិការ ឬ បំពេញបេសកកម្ម និងបំរើការងារ ។

- កងយោធពលខេមរភូមិន្ទអាចអនុញ្ញាតអោយប្រើប្រាស់អាវុធខ្លីយកតាមខ្លួនមួយនាក់ មួយដើមជាលក្ខណៈផ្ទាល់ខ្លួន ចាប់ពីថ្នាក់វរៈសេនីយ៍ឯកឡើងទៅ ។

- ប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់អាវុធខ្លី ( រូម ) របស់ស្ថាប័នកងឯកភាព ពេលចប់ប្រតិបត្តិការ ឬ បេសកកម្ម ( ត្រូវភ្ជាប់មកជាមួយលិខិតបេសកកម្ម ) ត្រូវយកមករក្សាទុកក្នុងស្ថាប័នកងឯកភាពសាម៉ីវិញ ។

- ករណីបាត់អាវុធខ្លី គ្រាប់ ដែលបាននិងកំពុងកាន់កាប់ប្រើប្រាស់ ហើយការបាត់នោះកើតឡើងនៅក្រៅអង្គភាព ត្រូវរាយការណ៍មិនលើសពី ២៤ ( ម្ភៃបួន) ម៉ោង ក្រោយពេលដឹងថាបាត់ ដល់សមត្ថកិច្ច ឬ រដ្ឋអំណាចនៅកន្លែងដែលបាត់ ហើយត្រូវមានសាក្សីដឹងឮម្នាក់ ឬ ពីរនាក់ទៅជាមួយផងនៅពេលរាយការណ៍ ។ ក្នុងករណីគ្មានសាក្សីសមត្ថកិច្ចនៅកន្លែងកើតហេតុ ត្រូវចុះត្រួតពិនិត្យនិងធ្វើកំណត់ហេតុដល់ទីកន្លែងដែលបាត់ ។

- របាយការណ៍ស្តីពីការបាត់អាវុធខ្លី និងគ្រាប់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់លំអិតទាក់ទិននឹងប្រភេទអាវុធខ្លី និងគ្រាប់ លេខចុះបញ្ជី ព្រមទាំងមូលហេតុ និងកាលៈទេសៈនៃការបាត់ ។

**ប្រការ ៤ : សមត្ថកិច្ចគ្រប់គ្រង ការចេញប័ណ្ណអាវុធខ្លី និងកាលបរិច្ឆេទ**

៤.១- គ្រប់ស្ថាប័នកងឯកភាព ត្រូវបំពេញបែបបទស្នើសុំប័ណ្ណអាវុធខ្លី តាមសមត្ថកិច្ចជំនាញ និងបានការទទួលស្គាល់របស់មេបញ្ជាការស្ថាប័នកងឯកភាព ឆ្លងតាមឋានានុក្រមមកក្រសួងការពារជាតិ ដើម្បីពិនិត្យផ្តល់ជូនសំរាប់ប្រើប្រាស់ ។ គំរោងស្នើសុំត្រូវភ្ជាប់មកជាមួយនូវបញ្ជីស្ថិតិ ដូចមានចែងក្នុងប្រការ ៣ ។

៤.២- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មានភារៈកិច្ចពិនិត្យលើគំរោងស្នើសុំរបស់បណ្តាស្ថាប័នកងឯកភាព នឹងសំរេចចេញប័ណ្ណអាវុធខ្លីអោយដល់ស្ថាប័នកងឯកភាពសំរាប់យកទៅប្រើប្រាស់ ។

៤.៣- គ្រប់ស្ថាប័នកងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ ត្រូវធ្វើបែបបទស្នើសុំប័ណ្ណអាវុធខ្លីថ្មី ដើម្បីបំពាក់អោយកងយោធពលខេមរភូមិន្ទដូចក្នុងប្រការ ១ អោយបានចប់សព្វគ្រប់នូវដំណាច់ខែ តុលា ឆ្នាំ ២០០៥ យ៉ាងយូរបំផុត ។

៤.៤- ប័ណ្ណអាវុធខ្លីចាស់ដែលចេញអោយប្រើប្រាស់ ដោយអគ្គបញ្ជាការបានចេញ ត្រូវអស់សុពលភាពនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៥ ។

**ប្រការ ៥** : ជនណាប្រើប្រាស់ប័ណ្ណអាវុធខ្លីក្លែងក្លាយ និងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៦** : ការត្រួតពិនិត្យលើការប្រើប្រាស់អាវុធខ្លី របស់កងយោធពលខេមរភូមិន្ទ ជាភារៈកិច្ចរបស់កងរាជ-អាវុធហត្ថ ។

**ប្រការ ៧** : ខ្លឹមសារនៃសេចក្តីណែនាំ សេចក្តីកំណត់ទាំងឡាយ ដែលផ្ទុយនិងខ្លឹមសារនៃសេចក្តីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨** : អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការកងទ័ពជើងទឹក មេបញ្ជាការកងទ័ពជើងអាកាស មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយក នាយក ប្រធាន មេបញ្ជាការស្ថាប័នកងឯកភាពចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន ត្រូវមានវិធានការផ្សព្វផ្សាយនិងអនុវត្តប្រកាសនេះ អោយបានម៉ឺងម៉ាត់និងមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>ផ្ញើជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៨
  " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

ទាហេរ.ផ្កាយមាស៤ ទៀ-បាញ់ ទាហេរ.ផ្កាយមាស៤.ភឹក-ប៊ុនឆៃ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

**លេខ: ១៥៣៧ អយក.ប្រក**

# ប្រកាស

## ស្តីពីការបើកអនុវិទ្យាល័យ " **ដូនដូង** "

## ស្ថិតនៅក្នុង ឃុំ បល្ល័ង្គ ស្រុក បារាយណ៍ ខេត្ត កំពង់ធំ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ បល្ល័ង្គ ស្រុក បារាយណ៍ ចុះថ្ងៃទី ០៤ មីនា ២០០៥ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្ត កំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

### សំរេច

**ប្រការ ១** : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " **ដូនដូង** " ស្ថិតនៅក្នុង ឃុំ បល្ល័ង្គ ស្រុក បារាយណ៍ ខេត្ត កំពង់ធំ ចាប់ពីឆ្នាំសិក្សា ២០០៥-២០០៦ តទៅ ។

**ប្រការ ២** : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣** : នាយក-នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ។

**ប្រការ ៤** : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ធំ និងនាយកអនុវិទ្យាល័យ សាមីមានភារកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ។

ភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០៥

បណ្ឌិត កុល ប៉េង

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពតិមាន "
- សាលាខេត្តកំពង់ធំ "ដើម្បីជាពតិមាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ នា.មចទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខៈ ១៥៣៨ អយក.ប្រក

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " **អូរត្នោត** "

ស្ថិតនៅក្នុង ឃុំ ងន ស្រុក សណ្តាន់ ខេត្ត កំពង់ធំ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ ងន ស្រុក សណ្តាន់ ចុះថ្ងៃទី ១៥ កញ្ញា ២០០៥ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្ត កំពង់ធំ
